លេខ ២ ថ្ងៃ ១ រោច ខែចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស. ២៥០៣
ត្រូវនឹងថ្ងៃទី ១ ខែមេសា គ.ស. ១៩៦១

# ពន្លឺពុទ្ធចក្រ

## ទស្សនាវដ្ដី ប្រចាំត្រីមាស

នៃ

## ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ

# LA LUMIERE BOUDDHIQUE

REVUE TRIMESTRIELLE

DE

L'ASSOCIATION DES BOUDDHISTES-CENTRE

DU CAMBODGE

Nº 2.— Samedi 1er Avril 1961

P.K.36
1961 - 2

លេខ ២ ថ្ងៃ ១ រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥០៣
ត្រូវនឹងថ្ងៃទី ១ ខែមេសា គ.ស. ១៩៦១

# ពន្លឺពុទ្ធចក្រ

## ទស្សនាវដ្ដី ប្រចាំត្រីមាស

## នៃ

## ពុទ្ធិកសមាគម-មជ្ឈមណ្ឌល កម្ពុជរដ្ឋ

# LA LUMIERE BOUDDHIQUE

REVUE TRIMESTRIELLE

DE

L'ASSOCIATION DES BOUDDHISTES-CENTRE

DU CAMBODGE

N° 2.— Samedi 1er Avril 1961

អាន « ពន្លឺពុទ្ធចក្រ » នាំឲ្យបានដល់នូវសិរីសួស្តី ដល់ខ្លួនផង ដល់គ្រួសាររបស់ខ្លួនផង ដល់សង្គមមនុស្សផង ។

ក្នុង « ពន្លឺពុទ្ធចក្រ » មានចុះអត្ថបទសុទ្ធសឹងមានសារប្រយោជន៍ទូលំទូលាយ ។

អត្ថបទ « ពន្លឺពុទ្ធចក្រ » សុទ្ធតែជាស្នាដៃរបស់អ្នកប្រាជ្ញយ៉ាងជំនាញ ៗ បានរៀបរៀង ។

ក្នុងគ្រួសារនីមួយ ៗ គួរមាន « ពន្លឺពុទ្ធចក្រ » ជាកល្យាណមិត្ត ។

« ពន្លឺពុទ្ធចក្រ » បណ្ដុះនាំនូវសន្តិធម៌ក្នុងបណ្ដាមនុស្សជាតិ ។


ចាងហ្វាងនៃការផ្សាយ : រ៉ាយ-ល្មុត

បណ្ណាធិការ : ណង់-លន់

ទីស្នាក់ការបណ្ដោះអាសន្ន : វត្តឧណ្ណាលោមភ្នំពេញ

Directeur de publication : Ray-Lomuth
Gérant : Nong-Lonn
Siège provisoire : Watt Unnalom Phnom-Penh
Cambodge

# ពន្លឺពុទ្ធចក្រ

## មាតិការឿង ទំព័រ


– ព្រះរាជក្រឹត្យទទួលស្គាល់ ពុ.ម.គ . . . . . . . . . . . . . ១
– រូបថតគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦១ . . . . . . . . . . . ៣
– កិច្ចការផ្សេងៗរបស់ ពុ.ម.គ រៀបរៀងដោយលោក រ៉ាយ-ល្មុត . . . . . . ៤
– ការសិក្សាព្រះពុទ្ធសាសនា រៀបរៀងដោយព្រះពោធិវង្ស ហា-តាត . . . . . . ១៥
– សេចក្ដីសម្រេចរបស់សង្ឃមហាសន្និបាត រៀបរៀងដោយគណៈកម្មការសង្ឃ . . . . ៣៨
– ទិដ្ឋិកថា រៀបរៀងដោយព្រះមុនីកោសល សូរ-ហាយ . . . . . ៤៦
– ដំណឹងផ្សេងៗ រៀបរៀងដោយលោក រ៉ាយ ល្មុត . . . . . . . . . ៥២

លេខ ២២៤ ក.ប.រ.ទ

ចុះថ្ងៃទី ៣/៦/៦០

ព្រះរាជអាណាចក្រកម្ពុជា

# ក្រឹត្យ

## ក្រុមប្រឹក្សារាជានុសិទ្ធ

បានទ្រង់យល់បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រ ។

បានទ្រង់យល់បានឃើញព្រះរាជប្រកាសលេខ ១១ ចុះថ្ងៃទី ៣១ ខែធ្នូ គ.ស. ១៩២៦ ត្រង់មាត្រា ១១៩ ជាដើម ។

បានទ្រង់យល់បានឃើញលក្ខន្តិកៈ នៃ ពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ ។

បានទ្រង់យល់បានឃើញកំណត់ហេតុពីថ្ងៃទី ១៩ ខែសីហា ១៩៥២ ស្ដីពីការតំកល់ទុក-លក្ខន្តិកៈ នៃសមាគមនេះនៅមន្ទីរក្រឡាបញ្ជីសាលាវិនិច្ឆ័យ ។

បានទ្រង់យល់បានឃើញព្រះរាជក្រឹត្យលេខ ១៨២ ក.ប.រ.ទ. ចុះថ្ងៃទី ១៩ ខែមេសា ១៩៦០ ស្ដីពីការតែងតាំងគណៈរដ្ឋមន្ត្រី ។

បានទ្រង់យល់បានឃើញនូវព្រះរាជក្រឹត្យលេខ ១២៨ ន.ស. ចុះថ្ងៃទី ៣ មេសា ១៩៥២ ស្ដីពីការរៀបចំជាថ្មីនូវក្រសួងធម្មការនិងសាសនៈសិក្សាធិការ

តាមសេចក្ដីស្នើសុំពីរដ្ឋមន្ត្រីក្រសួងធម្មការ

គណៈរដ្ឋមន្ត្រីបានយល់ព្រមផង :

## បង្គាប់

ប្រការ ១– ពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ ត្រូវទទួលស្គាល់ជាសមាគមមានប្រយោជន៍សាធារណៈ ហើយដោយហេតុនេះត្រូវមានសិទ្ធិទទួលអំណោយពីបុគ្គលដទៃបាន ។

ប្រការ ២ – អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនៈសិក្សាធិការត្រូវចាត់ការឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

ធ្វើនៅក្រុងភ្នំពេញ, នៅថ្ងៃទី ២ ៩ ៧ ឆ្នាំជូតទោស័ក ព.ស. ២៥០៣ ត្រូវនឹងថ្ងៃទី ៣ មិថុនា គ.ស. ១៩៦០

ក្រុមប្រឹក្សារាជានុសិទ្ធិ

សមាជិក :

ប្រធាន

ហត្ថលេខា : ពិន្ធូដឹមុងតេរូ

ឡាយព្រះហស្តលេខា : ស៊ីសុវត្ថិ-មុនីរ៉េត

: គ្រឿង-គាង

បានថ្វាយ ជូនសូមឡាយ ព្រះហស្តលេខា ហត្ថលេខា នៃក្រុមប្រឹក្សារាជានុសិទ្ធិ

រដ្ឋមន្ត្រីក្រសួងធម្មការ

ហត្ថលេខា : ង្វ-ត្រឿង

ទទួលបង្គាប់បញ្ជានៃ ក្រុមប្រឹក្សារាជានុសិទ្ធិ

នាយករដ្ឋមន្ត្រី

ហត្ថលេខា : ង្វ-ត្រឿង

តកល់ទុកនៅ :

- ក្រុមប្រឹក្សារាជានុសិទ្ធិ
- ក្រុមព្រះរាជាយុត្តកៈ
- លេខាធិការដ្ឋានសម្តេចព្រះឧបយុវរាជ
- រដ្ឋសភា
- ក្រុមប្រឹក្សាព្រះរាជអាណាចក្រ
- មន្ទីរស្តីការនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង
- ពុទ្ធិកសមាគមកម្ពុជរដ្ឋ
- មន្ទីរឯកសារ

ទិដ្ឋាការនៃក្រុមពិនិត្យនូវប្រាក់ចំណាយ

ថ្ងៃទី ១៦/៥/៦០. លេខ ១២៩២

ហត្ថលេខា : ង្វ-រៀង

ចំឡងដើម្បីចែក :

ជួស-អគ្គលេខាធិការ នៃ គណៈរដ្ឋមន្ត្រី-តាមបង្គាប់

ហត្ថលេខា : ង្វួន-ច្រឹក

បានចំឡងត្រឹមត្រូវតាមដើមហើយ

ជូនមក :

- សហជីវិនប្រធាន នៃ ពុទ្ធិកសមាគមកម្ពុជរដ្ឋ

សូមជ្រាបជាពត៌មាន ។

នាយការិយាល័យសាសនៈសិក្សាធិការ

រ៉ាយ-ប៊ុក



សមាសភាពគណកម្មាធិការនាយកសម្រាប់ ឆ្នាំ ១៩៦១

ពីឆ្វេងទៅស្តាំ ;

ជួរទី ១ = លោក រស់-ហែម, គង់-សារ, ឋាប-ខាន់ ហៅង៉ាន់, ភ៊យ. ស្មុគ, លោកស្រី ដោក-ស៊ីដេត, លោកស្រី ភ៊យ-ល្អុត និងលោកស្រី ផុស-ឆ្វង;

ជួរទី ២ = លោក អ៊ុក-ឌី, សោម-នៅ, សោម-ឆាំ, ប៊ុន-ថាន់, លោកស្រី អ៊ុក-ឌី, គង់-សារ និងលោកស្រី អ៊ឹង-គីមងន ;

ជួរទី ៣ = លោកស្រី ប៊ិន.ឈឹមសួន, ថាយ-គុល និងលោកស្រី សួរ-ធុំ ។

# កិច្ចការផ្សេង ៗ

របស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ

## ក) – អំពីមហាសន្និបាត

នៅថ្ងៃ ៣ រោចខែបុស្សឆ្នាំជូតទោស័ក ព.ស. ២៥០៣ ( ៣ មករា គ.ស. ១៩៦១ ) គណៈកម្មាធិការនាយកបានបាត់បែងផ្ដើមហាសន្និបាតប្រចាំឆ្នាំ ត្រឹមត្រូវទៅតាមបទបញ្ញត្តិប្រការ ២៩ , ៣០ , ៣១ , ៣២ និង ៣៣ នៃលក្ខន្តិកៈ របស់ ពុ.ស.ក. ។

កិច្ចការសំខាន់ ៗ ដែលគណៈកម្មាធិការនាយកប្រចាំឆ្នាំ ១៩៦០ បានបំពេញនោះ មានរៀបរាប់ស្រាប់ក្នុងសេចក្ដីថ្លែងការណ៍របស់ប្រធាន (ប៉ាយ - លុត) និងអគ្គហេរញ្ញិក (រស - ហែម) ខាងក្រោមនេះ ៖

## សេចក្ដីថ្លែងការណ៍

របស់ប្រធានគណៈកម្មាធិការនាយកនៃពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ ក្នុងឱកាសមហាសន្និបាត លើកទី ៩ នាថ្ងៃទី ៤ មករា គ.ស. ១៩៦១ ត្រូវនឹងថ្ងៃ ៣ រោចខែបុស្សឆ្នាំជូតទោស័ក ព.ស. ២៥០៣ ។

ខ្ញុំព្រះករុណា - ខ្ញុំតាងនាមគណៈកម្មាធិការនាយកនៃ ពុ.ស.ក. សូមថ្វាយបង្គំនិងសំដែងអំណរគុណចំពោះព្រះមហាថេរានុត្ថេរៈនិងសមាជិកសមាជិកាទាំងឡាយ ដែលបាននិមន្ត - អញ្ជើញយាងកុះករមកកាន់មហាសន្និបាតក្នុងពេលនេះ ។

តទៅនេះ ខ្ញុំព្រះករុណា - ខ្ញុំសូមថ្លែងនូវកិច្ចការសំខាន់ៗ ដែលគណៈកម្មាធិការនាយកប្រចាំឆ្នាំ ១៩៦០ បានបំពេញគឺ :

១ – តាមសេចក្ដីអំពាវនាវរបស់ក្រសួងធម្មការលេខ ១៥៩ ក-ធ - ចុះថ្ងៃទី ៤ កុម្ភៈ ១៩៦០ , គណៈកម្មាធិការនាយក បានចំណាយជាពិសេសនូវបច្ច័យចំនួន មួយពាន់រៀល , (១០០០'០០) ទិញទឹកសប្រគេនព្រះតេជព្រះគុណអនុគណ ខេត្តកោះកុង ក្នុងឱកាសដែលព្រះមហាថេរៈអង្គនេះមានធុរៈជាទម្ងន់ និមន្តមកព្យាបាលរោគាពាធនៅមន្ទីរពេទ្យកាល្មែត ។

២ – ក្នុងខែមេសា ១៩៦០ ពុ.ស.ក. បានរួបរួមជាមួយនឹងសមាគមមិត្តពុទ្ធិកវិទ្យាល័យនិមន្តព្រះសង្ឃ ៦៦ អង្គស្វាធ្យាយព្រះសត្តប្បករណ៍ឧទ្ទិសជាព្រះរាជកុសលថ្វាយចំពោះព្រះបរមសពព្រះករុណា ព្រះមហាកាត្តាន - កោដ្ឋ មានប្រគេនបច្ច័យនិងបរិក្ខារផ្សេងៗ បូករួមចំណាយទាំងអស់មានចំនួន បីពាន់ប្រាំពីររយហុកសិបពីរ

រៀល « ៣-៧៦២៛០០ » ។

៣– ក្នុងខែឧសភា ១៩៦០ បានរួបរួមពេញកំឡាំងក្នុងពិធីប្រចាំឆ្នាំនៃបុណ្យនមស្ការព្រះសក្យមុនីចេតិយ នៅមុខស្ថានីយរាជអយស្ម័យយាន នៅល្ងាចថ្ងៃ ១៤ កើតខែវិសាខបន្ទាប់ពីពិធីជាផ្លូវការ ពុ.ម.ក. យើងបានចាត់ចែងធ្វើពិធីវិសាខបូជារហូតដល់អធ្រាត្រ ។ ព្រឹកឡើងថ្ងៃ ១ រោច មានពិធីដាក់បាត្រព្រះសង្ឃប្រ-ហែល ២០០០ អង្គ ។ សមាគមយើងបានប្រៀតឱកាសនេះ រកបច្ច័យបានចំនួន មួយពាន់ប្រាំពីររយហុកសិបប្រាំពីររៀល « ១.៧៦៧៛០០ » បញ្ចូលក្នុងបេឡានៃសមាគម ។

៤– ដោយគណៈកម្មាធិការនាយក បានខំខ្នះខ្នែង រាជរដ្ឋាភិបាលបានទទួលស្គាល់ ពុ.ម.ក. ថាជាសមាគមមានប្រយោជន៍សាធារណៈ ដោយព្រះរាជក្រឹត្យលេខ ២២៤ កបរ ចុះថ្ងៃទី ៣ មិថុនា ១៩៦០ ។

៥– នៅខែសីហា ១៩៦០ ក្នុងឱកាសព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង ព្រះបរមសពព្រះករុណាព្រះមហាកាពួនកោដ្ឋ ដើម្បីសំដែងសេចក្ដីសោកស្ដាយនឹងកតញ្ញុតាចំពោះព្រះអង្គដែលជាព្រះបរមរាជូបត្ថម្ភក៏នឹងជាព្រះបរមរាជាធិបតីនៃ ពុ.ម.ក. គណៈកម្មាធិការនាយកបានចាត់ចែងបោះពុម្ពព្រះបរមឆាយាលក្ខណ៍ចំនួន៤០០០ ច្បាប់មានតម្លៃ ប្រាំមួយពាន់រៀល « ៦០០០៛០០ » ចែកអំណោយជាសាធារណៈដល់មហាជន ។

៦– ក្នុងខែសីហាដដែលនេះ គណៈកម្មាធិការនាយកបានជំនុំជាច្រើនលើកចាត់ចែងបង្កើតទស្សនាវដ្ដីមួយមាននាមថា "ពន្លឺពុទ្ធចក្រ" ដរាបលុះត្រាបានសម្រេច ដូចព្រះតេជព្រះគុណនិងអស់លោកអ្នកបានឃើញនូវរូបរាងប្រាកដដែលមានចែកនៅថ្ងៃនេះ ។ ទស្សនាវដ្ដីនេះសមាគមបានផ្ដួចផ្ដើមបង្កើតតាំងពីឆ្នាំ ១៩៥៤ម្ល៉េះ តែដោយតើបពះប្រទះនឹងឧបសគ្គជាច្រើនពេក ការផ្សាយក៏ត្រូវផ្អាករហូតមកដល់ថ្ងៃនេះ។ ទស្សនាវដ្ដី "ពន្លឺពុទ្ធចក្រ" មានសារៈសំខាន់ណាស់សូមសមាជិកសមាជិកាទាំងឡាយ មេត្តាជួយឧបត្ថម្ភផង ដោយអញ្ជើញចុះឈ្មោះជាប្រចាំឆ្នាំយកទៅអានឲ្យបានចំនួនច្រើន - គណៈកម្មាធិការនាយក សូមសំដែងអំណរគុណជាមុន ។

៧– ក្នុងខែសីហាដដែល ពុ.ម.ក. បានបំណាយបច្ច័យចំនួន មួយពាន់រៀល « ១០០០៛០០ » រៀបចំបានព្រហ្មទានចំនួនពីរ ប្រគេនដល់សមណនិស្សិតដែលប្រឡងពិនិត្យជាប់សញ្ញាប័ត្រចេញពីពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

៨– ក្នុងខែវិច្ឆិកា ១៩៦០ នៅពេលរដូវកឋិនទានជិតផុតហើយ ពុ.ម.ក. បានដំណើរថា វត្តរលាំង

ល្បូក (ហៅក្រស) ឃុំតាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ គឺជាវត្តនៅកៀនកោះដាច់ស្រយាលអំពីប្រជុំជន ពុំទាន់មានពុទ្ធបរិស័ទណា ផ្តើមផ្តើកកឋិនទានដង្ហែចូលសោះ ក៏បានយកចិត្តទុកដាក់ខ្វល់ខ្វាយរួបរួមគ្នានឹងសមាគមមិត្តពុទ្ធិកវិទ្យាល័យ ដោយមាន៖

– សម្តេចព្រះមហាសុមេធាធិបតី ជ.ណា. ជោតញ្ញាណោ

– ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត អគ្គាធិការពុទ្ធិកសិក្សានិងព្រះតេជព្រះគុណព្រះឧទាលីវង្ស កែវ-វ៉ាច់ បានជួយទំនុកបំរុងផង បានដង្ហែកឋិនទានទៅវេរប្រគេនចំពោះព្រះសង្ឃដែលគង់ចាំវស្សាអស់ត្រៃមាសក្នុងវត្តនោះ ។ ពិធីបុណ្យនេះបានរុងរឿងជាអធិយោក្រាភាពបរិបូណ៌ដោយបរិក្ខារផ្សេងៗ រួបរួមបច្ច័យសក្ការត្រៃមានចំនួនជាង បីម៉ឺនរៀល "៣០-០០០៛០០ ។ ក្នុងឱកាសនោះ សមាគមបានចំណាយអស់ចំនួន មួយម៉ឺនរៀល(១០.០០០៛០០) ។

៩– ក្នុងខែធ្នូ ១៩៦០ ពុ.ម.គា. ដោយមានសមាគមមិត្តពុទ្ធិកវិទ្យាល័យរួបរួមផង បានធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសលប្រគេនចំពោះវិញ្ញាណក្ខន្ធព្រះសពព្រះតេជព្រះគុណព្រះសាសនមុនីនាម មាស - គាង ចៅអធិការវត្តពិកទូវង្ស ក្រុងភ្នំពេញ មាននិមន្តព្រះសង្ឃចំរើនព្រះបរិត្ត-ទេសនាវេរកត្ត ។ល។ ក្នុងឱកាសនោះ សមាគមបានចំណាយចំនួន មួយពាន់រៀល (១០០០៛០០) តែដោយមានពុទ្ធបរិស័ទជាច្រើនបានជ្រះថ្លា ដល់បុណ្យនេះហើយស្រេចមាននៅសល់បច្ច័យចំនួនពីរពាន់ហាសិបរៀល (២០៥០៛០០) សមាគមទាំងពីរក៏បានលើកប្រាក់នេះបូជាទៅបេឡាបំរុងនៃវត្តនេះ សម្រាប់ចាយវាយក្នុងកិច្ចទំនុកបំរុងសពខេះតទៅ ។

១០ – នាកាលពេលប្រជុំថ្ងៃទី ៣០ ធ្នូ ១៩៦០ គណៈកម្មាធិការនាយកបានព្រមព្រៀងគ្នាចំណាយ មួយម៉ឺនរៀល "១០.០០០៛០០,, រៀបចាត់ចែងគ្រឿងគ្រង់ចង្ហាន់ប្រគេនព្រះសង្ឃក្នុងឱកាសបុណ្យអនុស្សាវរីយមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៧ ឆ្នាំ ១៩៦១ ។

ក្រៅពីកិច្ចការជាកុសលដែលបានត្រួសត្រាយខាងលើនេះ ខ្ញុំសូមកត់ចំណាំថា ពុ.ម.គា. បានទទួលពីមូលនិធិអាស៊ីនូវអំណោយចំនួន ប្រាំបួនម៉ឺនប្រាំបីពាន់ប្រាំបួនរយរៀល (៩៨-៩០០៛០០) មកបញ្ចូលគ្នានឹងធនធានសមាគមចំនួន បីម៉ឺនប្រាំមួយពាន់មួយរយប៉ែតសិបមួយរៀលហុកសិបប្រាំបីសេន (៣៦-១៨១៛៦៨) បូករួមទាំងអស់ជាប្រាក់ ១៣៥-០៨១៛៦៨ សម្រាប់ចេញថ្លៃអាហារូបករណ៍សមណនិស្សិតចំនួន ៦ រូបដែល

នៅរៀនសូត្របន្តវិជ្ជាឯបរទេសគឺ :

- នៅប្រទេសឥណ្ឌា ៣ រូប
- នៅប្រទេសស្រីលង្កា ២ –
- សហភាពភូមា ១ –

ចំណែកខាងការទាក់ទងនឹងជនបរទេស គណកម្មាធិការនាយកយើង ក្នុងខែកក្កដា ១៩៦០ បានទទួលលោកសង្ឃតីរអង្គនឹងគ្រហស្ថមួយរូបជាដំណាងនៃពុទ្ធសមាគមរុស្ស៊ី ព្រមទាំងបានទទួលលោកបណ្ឌិតវិស្វាវង់អាហ្គាវង់ ជាតិអាមេរិកាំង ធ្វើជាសាស្ត្រាចារ្យបង្រៀនខាងផ្នែកពុទ្ធសាសនានៅមហាវិទ្យាល័យយ៉ាល សហរដ្ឋអាមេរិក បានប្រាស្រ័យទាក់ទងគ្នាយ៉ាងស្និទ្ធស្នាលរកសេចក្តីចំរើនខាងព្រះពុទ្ធសាសនានៅប្រទេសទាំងពីរ ។

ក្នុងកិច្ចការពារព្រះពុទ្ធសាសនា ពុ.ម.កា. នាកាលប្រជុំរួមពីថ្ងៃទី ២៧ ឧសភា ១៩៦០ ទីប្រជុំបានបញ្ចេញមតិជាឯកច្ឆន្ទប្រឆាំងនឹងសៀវភៅមួយរបស់ឈ្មោះ គឹម-សេត ដែលមានចំណងជើងថា "ការតែងសេចក្តីខ្មែរ" ព្រោះសៀវភៅនេះ មានសេចក្តីប៉ះពាល់ជាខ្លាំងដល់ពុទ្ធសាសនា ហើយបានធ្វើពាក្យបណ្តឹងទៅកាន់រដ្ឋាភិបាល តែរហូតដល់សព្វថ្ងៃនេះឥតទាន់មានឃើញលទ្ធផលអ្វីទេ ។

## សាខាបច្ចុប្បន្នរបស់ ពុ.ម.កា.

១ – ខេត្តព្រៃវែង

២ – ខេត្តសៀមរាប

៣ – ខេត្តស្វាយរៀង

៤ – ខេត្តបាត់ដំបង

៥ – ខេត្តកំពត

៦ – ខេត្តស្ទឹងត្រែង

៧ – ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

៨ – ស្រុកសម្បូណ៌ ខេត្តក្រចេះ

# អំពីសមាជិកសមាជិកា

តាមសៀវភៅចេញសព្ទប័ណ្ណ "សញ្ញាប័ត្រ" មានចំនួន ២០៨៤ រូប

តាមសៀវភៅទារប្រាក់ភាគទានក្នុងឆ្នាំ ១៩៦០ — ៥៨៣ —

ក្នុងឆ្នាំ ១៩៦០ ចំនួនសមាជិកសមាជិកាបានកើន — ៣១ —

រីឯបាសាទិកសមាជិកនោះ មានច្រើនពាន់រូប ពុំបាច់ជូនចំនួនក្នុងទីនេះទេ ។

ក្នុងបណ្ដាសមាជិកសមាជិកាទាំងនេះ ខ្ញុំសូមរំលឹកថា ក្នុងឆ្នាំ ១៩៦០ ដែលកន្លងទៅថ្មីៗ នេះ មានសមាជិកសមាជិកាពិសេសបីប្រភេទគឺ :

១ – សមាជិកសមាជិកានៃគណៈកម្មាធិការនាយក "សូមមើលសមាសភាពនៃគណៈកម្មាធិការនាយកប្រចាំឆ្នាំ ១៩៦០" សមាជិកប្រភេទនេះ ក្នុងមុខងាររៀងខ្លួន មានសេចក្ដីជ្រះថ្លាបានយកចិត្តទុកដាក់ធ្វើពលិកម្មគ្រប់បែបយ៉ាងក្នុងការបំរើសមាគមយើងគ្រប់ពេលវេលា ។

២ – ពពួកសមាជិកសមាជិកា ដែលបានយកចិត្តទុកដាក់ខ្វល់ខ្វាយជាញឹកញាប់ជួយឲ្យសមាគមយើងបានចំរើន មានជួយក្រើនរំលឹកសមាជិកសមាជិកាផងគ្នាឲ្យបង់ប្រាក់ភាគទាននឹងជួយទារប្រាក់ភាគទានជាដើមគឺ :

១ – លោក យក់-ប៊ិន ធ្វើការនៅក្រុមព្រះនគរបាលជាតិ

២ – – ហ៊ុង-រុណ នាយក្រុមសង្គមកិច្ច វ. អ. យ. ក.

៣ – – ខៀវ-សុន កជ៌កយស្វ័យយាន

៤ – លោក ម៉ុ-សារ៉ន ផ្នែកខាងរោងចក្រ —

៥ – – ប៊ិន-ឈឹម-សួន ស៊ុរិយោដីក្រុង

៦ – – មាស-ហាំ សាលាក្រុង

៧ – – ខោល-ថៃ លេខាធិការដ្ឋានផ្ទាល់នៃសម្ដេចព្រះប្រមុខរដ្ឋ

៣ – សមាជិកសមាជិកាដែលមានសេចក្ដីជ្រះថ្លាជាពិសេសបានធ្វើអំណោយជូនសមាគមយើងគឺ :

| | | | |
|---|---|---|---|
| ១ – សម្ដេចព្រះរតនរាជធីតាព្រះពិន្ទុតាក | | ក្នុងមួយខែ | ១.៤៤០/០០ |
| ២ លោកស្រី | អ៊ុង-លន់ | — | ១០០-០០ |

| | | | |
|---|---|---|---|
| ៣- | លោក តាន់-ហុងអាន | ក្នុងមួយខែ | ១០០-០០ |
| ៤- | លោកស្រី ទី-មិញ | — | ១០០-០០ |
| ៥- | — សួរ-ធុំ | — | ១០០-០០ |
| ៦- | — ដោក-ស៊ីដេត | — | ១០០-០០ |
| ៧- | — តាន់-ឈុនហ៊ាង | ធ្វើអំណោយតែម្តង | ២-០០០-០០ |
| ៨- | លោក ប៉ុល-សាកាន | ក្នុងមួយខែ | ៥០-០០ |
| ៩- | — ដៃ-កុត | — | ៥០-០០ |
| ១០- | — ព្រំ-សាវ៉េត | — | ៥០-០០ |
| ១១- | — រស់-សយ | — | ៥០-០០ |
| ១២- | — ហ៊ុល-យ៉ឹម | — | ៣០-០០ |
| ១៣- | — មិន-ម៉ាង | — | ៣០-០០ |
| ១៤- | — គិម-យ៉ន | — | ២០-០០ |

ចំពោះសមាជិកសមាជិកាទូទៅ ជាពិសេសចំពោះសមាជិកសមាជិកាទាំងបីប្រភេទខាងលើនេះ ខ្ញុំព្រះករុណា-ខ្ញុំសូមសំដែងនូវសេចក្តីសរសើរ ហើយនឹងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅនេះ ១១

១១ទៀត ខ្ញុំសូមសំដែងនូវអំណរគុណចំពោះមូលនិធិអាស៊ី ដែលបានធ្វើអំណោយដូចបានខាងលើជូនសមាគមយើង ។

ខ្ញុំព្រះករុណា-ខ្ញុំសូមបញ្ជាក់ថា សមាគមយើងមានដំណើរទៅកាន់សេចក្តីចំរើនជាលំដាប់

សូមមហាសន្និបាតអភ័យទោស ដល់ខ្ញុំព្រះករុណា-ខ្ញុំទៅចុះ ព្រោះខ្ញុំព្រះករុណា-ខ្ញុំពុំអាចនឹងរៀបរាប់កិច្ចការរបស់គណៈកម្មាធិការនាយកប្រចាំឆ្នាំ ១៩៦០ ឲ្យវែងហួសហេតុ ។

ខ្ញុំព្រះករុណា-ខ្ញុំសូមបន្ទន់កាយ-វាចា-ចិត្ត ក្រាបថ្វាយបង្គំចំពោះ សម្តេចព្រះមហាសុមេធាធិបតី ជ-ណា. ជោតញ្ញាណោ ដែលព្រះអង្គបានជួយណែនាំគណៈកម្មាធិការនាយកប្រចាំឆ្នាំ ១៩៦០ គ្រប់ពេលវេលាដើម្បីសេចក្តីចំរើនគ្រប់យ៉ាងដល់ ពុ.ម.គ. ។

ទីបំផុតនេះ ខ្ញុំព្រះករុណា - ខ្ញុំសូមគោរពចំពោះព្រះត្រៃរត្ន ដោយកិរិយាគោរពនេះហើយនឹងដោយពាក្យសច្ចៈដូច្នេះ ខ្ញុំព្រះករុណា - ខ្ញុំសូមប្រមូលកងការកុសលទាំងអស់ ដូចមានរៀបរាប់ខ្លះខាងលើស្រាប់ ដែលគណៈកម្មាធិការនាយកបានបំពេញហើយនេះ ថ្វាយចំពោះសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះឧបយុវរាជ នរោត្ដម - សីហនុ ព្រះប្រមុខរដ្ឋ សូមព្រះអង្គទ្រង់បានប្រកបតែនឹងជោគជ័យមង្គលមហាប្រសើរគ្រប់ពេលវេលានេះមួយអន្លើ មួយអន្លើទៀត សូមពិភពលោកសម្បូណ៌ដោយសន្តិធម៌ឲ្យបានសព្វកាលជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ ។

## សេចក្ដីថ្លែងការណ៍

### អំពីស្ថានភាពហិរញ្ញវត្ថុរបស់លោកអគ្គហិរញ្ញិក នៅពេលធ្វើមហាសន្និបាតប្រចាំឆ្នាំគំរប់ទី ៩

### នាថ្ងៃទី ៤ មករា ១៩៦១

សូមថ្វាយបង្គំព្រះតេជព្រះគុណគ្រប់ព្រះអង្គ មានសម្ដេចព្រះមហាសុមេធាធិបតីព្រះសង្ឃនាយក ជាដើម ។

សូមជំរាបឯកឧត្ដម ព្រមទាំងអស់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយ

សូមទានជ្រាប សូមជ្រាប ។

ក្នុងឋានៈជាអគ្គហេរញ្ញិកនៃពុទ្ធិកសមាគមកម្ពុជរដ្ឋ ខ្ញុំព្រះករុណា-ខ្ញុំបាទ-ខ្ញុំ សូមប្រគេននឹងជូនស្ថានភាពហិរញ្ញវត្ថុនៃ ពុ ម.ក. ក្នុងការិយបរិច្ឆេទ ១៩៦០ ដែលកន្លងផុតទៅហើយ ដូចមានតទៅនេះ ៖

## អំពីប្រាក់ចំណូល

| | |
|---|---|
| ប្រាក់សល់ពីឆ្នាំ ១៩៥៩ គ្រឹមថ្ងៃទី ៣១-១២-៥៩ | ១០១-០៣៩៛៥២ |
| – ភាគទានក្នុងឆ្នាំ ១៩៦០ | ៦៤-៧៦៩-០០ |
| – ប្រតិលាភ | ២៥-២០០-០០ |
| – ដែលមូលនិធិអាស៊ីបានធ្វើអំណោយ | ៩៨-៩០០-០០ |

| | |
|---|---|
| – អំណោយអំពីបុណ្យនមស្ការព្រះសក្យមុនីចេតិយ | ១-៧៦៧:៥០ |
| – ឈ្នួលផ្ទះ | ២៤-០០០-០០ |
| រួមទាំងអស់ត្រូវជាប្រាក់ | ៣១៥-៦៧៦.០២ |

## អំពីប្រាក់បំណាយ

| | |
|---|---|
| បៀវត្សរ៍បុគ្គលិកពីររូប | ៤៤-៤០០-០០ |
| ទិញសម្ភារៈផ្សេងៗ មានក្រដាសជាដើមសម្រាប់ប្រើ | ៦៨៤-០០ |
| ថ្លៃអាហារូបករណ៍សមណនិស្សិតទាំង ៦ រូប | ១៣៥-០៨១-៦៨ |
| ទិញទឹកក្រូច-កកប្រគេនមន្ត្រីសង្ឃបុណ្យអនុសំវច្ឆរមហាសន្និបាត | ១-៧១៩-០០ |
| ជួយឧបត្ថម្ភលោកគ្រូអនុគណខេត្តកោះកុង | ១ ០០០·០០ |
| កម្រងផ្កាដង្ហែព្រះសពព្រះមុនីកោសល មេគណខេត្តកណ្តាល | ៤៥០-០០ |
| ថ្លៃផ្ញើលិខិតអនុសិដ្ឋនិងលិខិតផ្សេងៗ | ២៥០-០០ |
| ធ្វើទក្ខិណានុប្បទានប្រគេនព្រះសពព្រះសាសនមុនី មាស-កាង | ១០០០-០០ |
| ឈ្នួលមនុស្សចាំផ្ទះរបស់សមាគម | ១.៨០០-០០ |
| ធ្វើបុណ្យថ្វាយព្រះរាជកុសលព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ | ២.៥០៨-០០ |
| ចេញថ្លៃអាកាសយានឲ្យនិស្សិត គួច-គីឡេង | ៣.៧៥០-០០ |
| ថ្លៃកេសជ្ជៈទទួល លោកបណ្ឌិត រិស្ហារដ៍ អា·ហ្គារដ៍ | ៨៧·០០ |
| ធ្វើធុងទឹកនៅផ្ទះរបស់សមាគម | ៤២០·០០ |
| ថ្លៃបោះពុម្ពព្រះបរមឆាយាលក្ខណ៍ព្រះមហាកាញ្ចនកោដ្ឋ | ៦ ០០០-០០ |
| ថ្លៃវត្ថុផ្សេងៗ នឹងថ្លៃដឹកនាំព្រះបរមឆាយាលក្ខណ៍ | ១១៨·០០ |
| ចូលធ្វើព្រហ្មទានជាមួយនឹងសមាគមមិត្តពុទ្ធិកវិទ្យាល័យ | ១.០០០ ០០ |
| ចំណាយធ្វើបុណ្យកឋិនទានដង្ហែ ទៅវត្តលាំងឈូក «កំពង់ស្ពឺ» | ១០.០០០-០០ |

ទទួលបង្ហាន់មន្ត្រីសង្ឃដែលនិមន្តមកកាន់អនុសំវច្ឆរមហាសន្និបាត ១០.០០០'០០

ធ្វើអំណោយទៅគណៈកម្មការទស្សនាវដ្តី "ពន្លឺពុទ្ធចក្រ" ៥០.០០០-០០

រួមចំណាយទាំងអស់ ២៧០-២៦៧'៦៨

កាត់ប្រាក់ចំណាយនេះចេញអំពីចំណូល ឃើញនៅសល់ប្រាក់ក្នុងហិបត្រឹមថ្ងៃទី៣១ធ្នូ១៩៦០ចំនួន ៖

៣១៥.៦៧៦'០២–២៧០.២៦៧'៦៨= ៤៥.៤០៨'៣៤

ដូចអំពីនេះ ខ្ញុំព្រះករុណា-ខ្ញុំបាទ-ខ្ញុំ សូមប្រគេន សូមជូនដំណឹងថា ត្រឹមថ្ងៃទី៣១ធ្នូ១៩៦០ ពុទ្ធិកសមាគមកម្ពុជរដ្ឋ មានធនធានដូចខាងក្រោមនេះ៖

ប្រាក់ផ្ញើដើម្បីយកប្រតិលាភ ៨៦០-០០០'០០

— — នៅធនាគារ ៨៧០-០០

— សល់ពីការិយបរិច្ឆេទ ១៩៦០ ៤៥.៤០៨-៣៤

រួមទាំងអស់ត្រូវជាប្រាក់ ៩០៦.២៧៨'៣៤

នៅទីអវសាន ខ្ញុំព្រះករុណា-ខ្ញុំបាទ-ខ្ញុំ សូមផ្ញើសេចក្តីសង្ឃឹមយ៉ាងមាំលើព្រះតេជព្រះគុណគ្រប់អង្គ និងអស់លោក-អ្នកទាំងឡាយថា មុខជាជួយជ្រោមជ្រែងពេញទំហឹង ដោយជួយជាវទស្សនាវដ្តី "ពន្លឺពុទ្ធ-ចក្រ" ដើម្បីឲ្យ ពុ.ម.ក. ចេះតែមានសេចក្តីចំរើនទៅអនាគតជាកិយ្យាភាព ។

១|- សមាសភាពនៃ

# គណៈកម្មាធិការនាយកប្រចាំឆ្នាំ ១៩៦១

មហាសន្និបាតនាថ្ងៃទី ៣ មករា គ.ស. ១៩៦១ បានជ្រើសតាំងសមាជិកនៃគណៈកម្មាធិការនាយក ចំនួន២០រូប ។ តមក ដោយអនុលោមទៅតាមបទបញ្ញត្តិប្រការ៩ ទី១០ នៃបទបញ្ជារបស់ ពុ.ម.ក. សមាជិកទាំង ២០រូបខាងលើនេះ បានរួមប្រជុំគ្នានៅថ្ងៃទី១៦ មករា គ.ស. ១៩៦១ ហើយបានសម្រុះសម្រួលព្រមព្រៀងគ្នាចែកមុខងារដូចតទៅ៖

| | | |
|---|---|---|
| ១– លោក | ក៉យ-លួត | ជាប្រធាន |
| ២– – ស្រី | ជោក-ស៊ីផេត | ជាអនុប្រធានទី ១ |
| ៣– – | គង់ សរ | – ទី ២ |
| ៤– – | ចាប-ខាន់ ហៅ ឆ៉ាន់ | – ទី ៣ |
| ៥– លោក | ប៊ុន-ចាន់ | អគ្គលេខាធិការ |
| ៦– – | នូ-ឯម | លេខាធិការទី ១ |
| ៧– – ស្រី | អ៊ុក-ជី នាមដើម បួយ-ស៊ីវអេង | – ទី ២ |
| ៨– លោក | សេ-ហៃម | អគ្គហេរញ្ញិក |
| ៩– – | បេ យាន | ហេរញ្ញិកទី ១ |
| ១០– – | អ៊ុង-គីមឆន | – ទី ២ |
| ១១– លោក | ទាជាវ-លី | សួនការ |
| ១២– „ | សោម-នៅ | – |
| ១៣– „ | សោម-ជាំ | – |
| ១៤– លោកស្រី | ក៉យ-លួត | – |
| ១៥– – | អ៊ឹង-គីមឆន | – |
| ១៦– – | គង់-សរ នាមដើម សម-ណៃ | – |
| ១៧– – | ចាយ-ធុល – ក៉ន់ ចិត្តសិរ | – |
| ១៨– – | ជុស-ជួង – ក៉ន់ ធំ | – |
| ១៩– – | ស្បូរ-ធុំ | – |
| ២០– – | ប៉ិនឈិម-សួន | – |

## គ).– ទីប្រឹក្សារបស់ ពុ.ម.ក. សម្រាប់ឆ្នាំ ១៩៦១

| | | |
|---|---|---|
| ១– | សម្តេចព្រះមហាសុមេធាធិបតី ជ.ណ. | ជោតញ្ញាណោ |
| ២– | ព្រះពោធិវង្ស ហួត-តាត | វជិរប្បញ្ញោ |
| ៣– | ព្រះធម្មលិខិត មុិង-សែស | ចន្ទធម្មោ |
| ៤– | ព្រះឃោសធម្ម កៅ-ស៊ុម | សិរិបញ្ញោ |
| ៥– | ព្រះឧបាលិវង្ស កែវ-ភ៉ន់ | សុវណ្ណត្ថេកេ |
| ៦– | ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ-សុភ្គាជ | ធម្មាកមោ |

> គេសឹងអាចព្យាយាមកិនបំពញ់យកប្រេងអំពីខ្សាច់បាន មួយវិញទៀតប្រសិនបើស្រេកខ្លាំង ក៏សឹងតែអាចផឹកទឹកក្នុងថ្ងៃបណ្តើរក្ខូនបាន ;
>
> គាប់ជួនប្រសិនបើ ត្រាច់រង្គាត់សព្វប្រកល្អកទៅ ប្រហែលជាអាចរកស្នែងទន្សាយបាន ;
>
> ប៉ុន្តែគេមិនអាចបំពេញចិត្តមនុស្សល្ងង់រង្វើងឆ្វេងតែផ្តាស់បានឡើយ ៗ
>
> ចាកគ.ល. ៥ នៃនីតិសតកៈរបស់ភត្តិហរី

# ការសិក្សាខាងព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា
# ក្នុងសម័យបុរាណ និង សម័យបច្ចុប្បន្ន

**ការសិក្សាខាងព្រះពុទ្ធសាសនា សម័យបុរាណ** កាលពីសម័យបុរាណ ភិក្ខុសាមណេរទាំងឡាយ ដែលសិក្សារៀនសូត្រព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក តែក្នុងវត្តអារាម ឥតមានសាលាសម្រាប់រៀនដោយឡែកទេ គឺរៀននៅទីកុដិផ្ទាល់នៃលោកអាចារ្យអ្នកបង្រៀន ឥតមានតុះសម្រាប់អង្គុយរៀនទេ ឥតមានតុះសម្រាប់អាចារ្យទេ គឺរៀនអង្គុយផ្ទាល់លើកម្រាល ៗ ភិក្ខុសាមណេរអ្នករៀន យកសាស្ត្រាស្លឹករឹតដាក់លើជើងអាធារ ហើយរៀនទន្ទេញតាមបង្គាប់លោកអាចារ្យ ៗ មុនដំបូងរៀនមេសូត្រ រួចរៀនមូលកច្ចាយនៈ ហើយទើបរៀនគម្ពីរធម្មបទដ្ឋកថាប្រែពីបាលីជាខ្មែរតាមលោកអាចារ្យ ៗ បើរៀនចប់គម្ពីរធម្មបទហើយ អាចរៀនទៅគម្ពីរមង្គលត្ថទីបនី, សារត្ថសង្គហៈនិងគម្ពីរផ្សេង ៗ ទៅទៀតមានគម្ពីរវិសុទ្ធិមគ្គជាដើម ៗ

ការសិក្សារៀនសូត្ររបស់ភិក្ខុសាមណេរក្នុងសម័យមុននោះ ពុំមានការសរសេរតែងសេចក្តីទេ មានតែការទន្ទេញឲ្យចាំតាមបង្គាប់អាចារ្យប៉ុណ្ណោះ ការទន្ទេញឲ្យចាំនោះយូរ ៗ ទៅនាំឲ្យមានលទ្ធផលដល់ភិក្ខុសាមណេរអ្នកសិក្សាដែរ គឺបានយល់ចូលចិត្តស្គាល់ការខុសត្រូវ ដោយអាស្រ័យសេចក្តីពន្យល់របស់លោកអាចារ្យផង ដោយខំទន្ទេញឲ្យចាំផង ប៉ុន្តែការសិក្សាដូច្នោះ ទំរាំតែបានទទួលលទ្ធផល ត្រូវសិក្សាច្រើនឆ្នាំណាស់ ៗ

ក្នុងរង្វង់ការសិក្សាសម័យបុរាណនោះ ពុំមានក្បួនខ្នាតសម្រាប់សិក្សាបរិបូណ៌ឡើយ មានតែគម្ពីរស្លឹករឹតប៉ុណ្ណោះឯង ៗ ភិក្ខុសាមណេរទាំងឡាយដែលសិក្សាក្នុងជំនាន់នោះ មិនមានចំនួនច្រើនដូចបច្ចុប្បន្ននេះឡើយ ព្រោះក្នុងសម័យនោះ ការសិក្សារៀនសូត្រព្រះត្រៃបិដកនេះ ជាការកម្របំផុត ដោយហេតុមានការខ្វះខាតគ្រប់មុខគឺ:

១– អាចារ្យអ្នកបង្រៀន មិនសម្បូរទេ

២– គម្ពីរក្បួនច្បាប់សម្រាប់បង្រៀនក៏ក្រ មិនសម្បូរដូចគ្នា

៣– ការឧបត្ថម្ភពីរាជការក៏គ្មាន

ដោយហេតុដូចខាងលើនេះ ទើបភិក្ខុសាមណេរអ្នកសិក្សាទាំងឡាយ បានជួបនឹងសេចក្តីលំបាក ហើយទ្រាំបន្តការសិក្សាឲ្យដល់ទីបំផុតមិនបាន ក៏បោះបង់ការសិក្សាចោលទៅ ពុំសូវមានអ្នកសិក្សាដែលខំប្រឹងតស៊ូរហូតដល់ទីបំផុត បានជាភិក្ខុសាមណេរអ្នកសិក្សាពុំមានច្រើនដូចក្នុងបច្ចុប្បន្ននេះ ៗ

ក្នុងសម័យនោះ ភិក្ខុសាមណេរណា រៀនបានចេះដឹងព្រះត្រៃបិដក គឺអាចប្រែពីបាលីមកជាខ្មែរបាន ភិក្ខុសាមណេរនោះមានតម្លៃណាស់ គេអាចទុកជាបណ្ឌិតអ្នកប្រាជ្ញព្រោះកម្រមានរៀនចេះ បើបានចេះមួយៗ ទុកជាអ្នកមានភ័ព្វវាសនាធំណាស់ ។

ការរៀនសូត្រក្នុងសម័យនោះ ព្រះករុណាជាអម្ចាស់ជីវិត ដែលព្រះអង្គជាអគ្គពុទ្ធសាសនូបត្ថម្ភក៍ ទ្រង់ព្រះរាជទានទិព្វភត្តចំពោះភិក្ខុសាមណេរទាំងឡាយដែលសិក្សាព្រះត្រៃបិដកគ្រប់វត្តនៅក្រុងភ្នំពេញ ក្នុង ១ រូប ចំនួន ៣០ សេន គឺ ៣ កាក់ពល់ខែជាតម្លៃប្រេងកាត ដើម្បីឲ្យភិក្ខុសាមណេរទាំងឡាយខំប្រឹងសិក្សារៀនសូត្រ ។

ម្យ៉ាងទៀតព្រះករុណាជាអម្ចាស់ជីវិត ព្រះអង្គមិនមែនជួយឧបត្ថម្ភត្រឹមតែប្រគេនតម្លៃប្រេងកាតដល់ភិក្ខុសាមណេរទាំងឡាយដែលសិក្សាព្រះត្រៃបិដកប៉ុណ្ណោះទេ ព្រះអង្គទ្រង់បានរៀបចំទីកន្លែងតាក់តែងឲ្យមានក្រុមរាជបណ្ឌិតអ្នកចេះព្រះត្រៃបិដកបង្រៀនដល់ភិក្ខុសាមណេរទាំងឡាយផងទៀត ប៉ុន្តែទោះបីជួយបោះក៏ដោយគង់តែភិក្ខុសាមណេរអ្នកសិក្សាមិនមានចំនួនច្រើនឡើយ ។

ការឧបត្ថម្ភនៃព្រះករុណាជាអម្ចាស់ជីវិតជាគំរូបែបនេះ នាំឲ្យពុទ្ធបរិស័ទទាំងឡាយខ្លះ ដែលមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាយកតម្រាប់តាម បានអញ្ជើញលោកអាចារ្យទៅបង្រៀនព្រះត្រៃបិដកដល់ភិក្ខុសាមណេរនៅគេហដ្ឋានរបស់ខ្លួន ហើយទំនុកបំរុងដោយចតុប្បច្ច័យតាមកម្លាំងសទ្ធារៀងខ្លួន តែពុំមានច្រើនប៉ុន្មានដែរ ។

ការសិក្សារៀនសូត្រក្នុងសម័យនោះ ពុំមានជាផ្លូវការទេ គឺជាការសិក្សារបស់ឯកជនពិតៗ ព្រោះលោកអ្នកបង្កើតឲ្យមានការសិក្សានៅតាមវត្តអារាមក្តី តាមគេហដ្ឋានរបស់ខ្លួនក្តី សុទ្ធតែបង្កើតឡើងដោយសទ្ធាជ្រះថ្លារបស់ខ្លួន ទាំងភិក្ខុសាមណេរដែលខំរៀនសូត្រក្នុងសម័យនោះ ក៏ខំរៀនដោយសទ្ធារបស់ខ្លួនមានបំណងចង់ឲ្យបានចេះដឹងតែម្យ៉ាងប៉ុណ្ណោះ ។

ម្យ៉ាងទៀត ការសិក្សាក្នុងសម័យនោះ ឥតមានកម្មវិធី ឥតមានកាលវិភាគទេ ព្រមទាំងឥតមានកំណត់កាលសិក្សាទេ ។ ការសិក្សានោះ ស្រេចនៅកម្លាំងរបស់ភិក្ខុសាមណេរអាចសិក្សាបានប៉ុន្មានឆ្នាំក៏សិក្សាទៅ ឥតមានកម្រិតប៉ុណ្ណោះប៉ុណ្ណោះឆ្នាំឡើយ ព្រោះការសិក្សាសម័យនោះសុទ្ធតែក្រៅផ្លូវការទាំងអស់ ទោះបីអ្នកសិក្សាបានប្រឡង (ដេញប្រយោគ) ជាប់បានទទួលឋានៈជាទីមហា ៣ ប្រយោគក្តី ៤ ប្រយោគជាដើមក្តី ក៏គ្រាន់តែជាកិត្តិយសប៉ុណ្ណោះឯង ។

# អំពីការប្រឡងក្នុងសម័យបុរាណ

យូរៗ មានការរៀបចំប្រឡងម្តង, ការប្រឡងក្នុងសម័យបុរាណមិនមែនដូចក្នុងសម័យបច្ចុប្បន្ននេះទេ ។ ការប្រឡងក្នុងសម័យនោះនៅក្នុងការឧបត្ថម្ភនៃព្រះករុណាជាអម្ចាស់ជីវិត ។ របៀបនៃការប្រឡងនោះមិនមានការសរសេរទេ មានតែការប្រែពីបាលីជាខ្មែរដោយផ្ទាល់មាត់តែម្តង, គេហៅថា «ដេញប្រយោគ» ។ រីឯមេប្រយោគគឺជ្រើសរើសយកព្រះមហាថេរជាព្រះរាជាគណៈថ្នាក់ខ្ពស់ ដែលចេះដឹងព្រះត្រៃបិដកមាំមួនទនឹងលោកអាចារ្យដែលចេះដឹងជាគ្រហស្ថខ្លះ មករួបរួមធ្វើជាមេប្រយោគ ។

ការប្រឡងក្នុងសម័យនោះ ឥតមានច្បាប់បញ្ញត្តិថា ព្រះសង្ឃដែលសិក្សារៀនសូត្រត្រូវប្រឡងរាល់ឆ្នាំ ឬក៏កំណត់ប៉ុណ្ណេះប៉ុណ្ណោះឆ្នាំត្រូវប្រឡងម្តងដូច្នេះឡើយ ។ ការប្រឡងនោះស្រេចនៅព្រះករុណាជាអម្ចាស់ជីវិតទ្រង់សព្វព្រះរាជហឫទ័យ ចាត់ការឲ្យប្រឡងតាមសេចក្តីស្នើពីគណៈសង្ឃដោយគណៈរដ្ឋមន្ត្រីជួយចាត់ការឲ្យមានរបៀបរៀបរយផង ។

រីឯរបៀបនៃការប្រឡងនោះដូច្នេះគឺ មុនដំបូងគេរើសប្រយោគដែលមានក្នុងគម្ពីរធម្មបទដ្ឋកថា (គម្ពីរស៊ឹករឹត) ចំពោះអត្ថបទដែលមានសេចក្តីក្រៗ ហើយលំបាកបន្តិច ក្នុងប្រយោគនីមួយៗ ចំនួន ៤ សន្លឹកស៊ឹករឹត គេរើសឲ្យមានច្រើនប្រយោគ ឲ្យសមល្មមតាមចំនួនភិក្ខុសាមណេរជាបេក្ខសមណៈអ្នកប្រឡង គឺឲ្យមានប្រយោគបីៗ សម្រាប់បេក្ខសមណៈ ១ រូបៗ ព្រោះបេក្ខសមណៈ ១ រូប ត្រូវប្រឡងឲ្យបាន ៣ ប្រយោគ ប៉ុន្តែប្រឡងក្នុង ១ ដងតែ ១ ប្រយោគទេ ប្រឡង ៣ ដងទើបបានបីប្រយោគ ។ ប្រយោគទាំងអស់ដែលរើសហើយ ត្រូវសរសេរលើក្រដាស ហើយបោះត្រារួចដាក់ក្នុងស្រោមបិទឲ្យជិត ។ គេយកស្រោមប្រយោគទាំងអស់នោះដាក់ក្នុងហិប១ ដល់ថ្ងៃប្រឡង គេយកហិបប្រយោគនោះទៅដំកល់នៅចំពោះព្រះភក្ត្រព្រះពុទ្ធរូបក្នុងវិហារធំជាទីប្រឡង ។

រីឯបេក្ខសមណៈ គឺភិក្ខុសាមណេរអ្នកប្រឡង ទោះមានចំនួនច្រើនរាប់រយក៏ដោយ ក្នុង ១ ថ្ងៃៗ អនុញ្ញាតឲ្យបេក្ខសមណៈត្រឹមតែ ៤ រូបចូលប្រឡង ។ បេក្ខសមណៈទាំង ៤ រូបនោះ ត្រូវទៅចាប់ប្រយោគពីព្រឹក លុះចាប់បានប្រយោគណាហើយ គេប្រគល់គម្ពីរមួយគណ្ឋៗ ឲ្យទៅនៅក្នុងកន្ទុង ១ ដោយឡែក មានក្រុមសង្ឃការីយាមល្បាតមិនឲ្យអ្នកណាទៅជិត មានឧបដ្ឋាក់ធាន់ ដោយព្រះករុណាជាម្ចាស់ជីវិតទ្រង់

ប្រោសព្រះរាជទាន ។ បេក្ខសមណៈទាំង ៤ រូបនោះអាចពិគ្រោះសាកសួរគ្នាបាន ។ លុះដល់ម៉ោង ២ រសៀល ជាពេលដែលអស់លោកជាមេប្រយោគជួបជុំហើយ ក្នុងពេលនោះមានគណៈវដ្តមន្ត្រី ឬ តំណាងទៅជួបជុំផង ក្នុងវិហារធំជាទីប្រឡង លុះចំណេរកាលតមក ដោយមានវិហារព្រះកែវមរកតកើតឡើងហើយក៏ត្រូវប្រជុំប្រឡងក្នុងវិហារព្រះកែវមរកតនេះ ភិក្ខុសាមណេរក្រៅពីបេក្ខសមណៈចូលទៅអង្គុយស្ដាប់បាន ។ រីឯលោកជាមេប្រយោគអង្គុយដង្ហែគ្នា ហើយមានអាចារ្យគ្រហស្ថ ១ ផ្នែកអង្គុយផ្ទៀងម៉ោង, ម៉ោងពេលដែលប្រឡងនោះកំណត់ត្រឹម ១ ម៉ោងក្នុងបេក្ខសមណៈ ១ រូប, ដែលចូលទៅប្រឡងយកប្រយោគទី ១ ។ បើបេក្ខសមណៈនោះ ប្រែមិនចប់ក្នុងពេល ១ ម៉ោង គឺថារកផ្លូវចេញមិនរួចអស់ ១ ម៉ោង ឈ្មោះថាធ្លាក់ប្រយោគហើយ ទឹងត្រូវឈប់ខានប្រឡងរហូតទៅ ។ បើស្ទុះរួចក្នុងរយៈកាលមុន ១ ម៉ោង ឬ ស្មើ ក៏ទុកជាបានជាប់ប្រយោគទី ១ អ្នកបានប្រយោគទី ១ ត្រូវប្រឡងបន្តទៅទៀតក្នុងថ្ងៃទី ២ បើធ្លាក់ក្នុងថ្ងៃទី ២ ត្រូវឈប់រហូត បើជាប់ប្រយោគទី ២ ត្រូវប្រឡងបន្តទៅទៀតក្នុងថ្ងៃទី ៣ យកប្រយោគទី ៣ បើធ្លាក់ប្រយោគទី ៣ ហើយប្រយោគទី ១ ទឹងទី ២ ដែលប្រឡងជាប់ពីថ្ងៃមុន ក៏ទុកដូចជាធ្លាក់ដែរ លុះតែក្នុងថ្ងៃទី ៣ បានជាប់ប្រយោគទី៣ ទៀត ទើបទុកជាបានការ ។ បេក្ខសមណៈដែលប្រឡងជាប់ទាំង ៣ ប្រយោគនោះត្រូវបានងារជាព្រះមហា ៣ ប្រយោគ (ឯមហា ១ ប្រយោគ ឬ ២ ប្រយោគគ្មានទេ) ។ បេក្ខសមណៈដែលប្រឡងដូចគ្នាទាំងអស់ក្នុង ១ ថ្ងៃយកតែ ៤ រូប ដោយគិតពេលម៉ោងត្រឹម ៤ ម៉ោង តាំងពីម៉ោង ២ រសៀលទៅទល់នឹងម៉ោង ៦ ល្ងាច ។ ឯពេលព្រឹកមិនប្រឡងទេ ព្រោះទុកពេលឲ្យបេក្ខសមណៈគិតទុកមុនផង ហើយជាពេលនាំឲ្យមានកង្វល់ដល់អាហារភោជនផង ។

## របៀបប្រឡង (ដេញប្រយោគ)

បេក្ខសមណៈដែលប្រឡងត្រូវចូលទៅអង្គុយបត់ជើងនៅចំពោះមុខអស់លោកជាមេប្រយោគ មានសាស្ត្រាស្លឹករឹត ១ ខ្សែដំកល់លើសំបកគម្ពីរដែលដាក់លើជើងអាធារ សាស្ត្រា ១ ខ្សែនោះមានអត្ថបទដែលបេក្ខសមណៈចាប់ស្លាកពីព្រឹក ហើយបានពិនិត្យមើលហើយស្រេច ។ ចំណែកមេប្រយោគគ្រប់អង្គក៏មានសាស្ត្រាស្លឹករឹត ១ ខ្សែ ១ មានអត្ថបទដូចគ្នាដែរ ចាំផ្ទៀងចាំសួរ ចាំសង្កត់ឲ្យបេក្ខសមណៈផ្លាស់ប្រយោគផ្លាស់សព្ទ ។

កាលបើដល់កំណត់ពេលម៉ោងអាចារ្យគ្រហស្ថក៏ពិនិត្យម៉ោងឲ្យត្រឹមត្រូវ ហើយលោកអធិបតីមេប្រយោគ

បានប្រាប់ថាដល់ពេលហើយប្រែទៅចុះ ។ ក្នុងពេលនោះបេក្ខសមណៈអ្នកប្រឡងចាប់អានបាលី ១ ប្រយោគ ហើយប្រែបាលីជាខ្មែរប្រែរបៀបលាតប្រយោគ ។ ក្នុងឱកាសដែលបេក្ខសមណៈកំពុងប្រែនោះ លោកជាមេប្រយោគមានច្រើនអង្គផ្ទៀងស្តាប់ បើលោកមេប្រយោគអង្គណាលោកមិនព្រមយក លោកប្រាប់ថា មិនយកទេ ប្រយោគបែបនេះឬសព្ទប្រែបែបនេះ, បេក្ខសមណៈត្រូវរើប្រយោគប្រែជាថ្មីទៀត ឬផ្លាស់សព្ទជាថ្មីទៀត បេក្ខសមណៈដែលមិនសូវចេះមិនអាចនឹងដោះស្រាយបាន ទោះបីមេប្រយោគឲ្យន័យខ្លះហើយក៏នៅតែពុំយល់ រហូតអស់ពេលម៉ោង បេក្ខសមណៈនោះត្រូវធ្លាក់ ។ បើបេក្ខសមណៈចេះដឹងច្រើន អាចរើប្រយោគផ្លាស់សព្ទប្រែភ្លាម ៗ ទៅមុខរហូតមិនទាំងអស់ពេលម៉ោងផង គឺបានប្រែចប់ដោយមេប្រយោគសង្កត់មិនជាប់ បេក្ខសមណៈនោះឈ្មោះថាបានប្រឡងជាប់ ។ រីឯមេប្រយោគ ៤-៥ អង្គនោះមិនមែនសួរតែម្នាក់ឯងទេ គឺមេប្រយោគណាសួរក៏បានស្រេចតែនឹងត្រូវការ ជួនកាលសួរគ្រប់តែអង្គ មួយសួរហើយ មួយសួរទៀត មួយសង្កត់ទៀត បើបេក្ខសមណៈមានសមត្ថភាពអង់អាច មេប្រយោគសប្បាយណាស់សួរគ្រប់អង្គសង្កត់គ្រប់អង្គ ប៉ុន្តែសង្កត់មិនជាប់បេក្ខសមណៈប្រភេទនេះ បានជាប់ប្រយោគដោយរុងរឿងព្រមទាំងបានទទួលសេចក្តីសរសើរអំពីមេប្រយោគភ្លាម ៗ ។

ក្នុង ១ ថ្ងៃប្រឡងបានតែបេក្ខសមណៈ ៤ រូបប៉ុណ្ណោះ ភិក្ខុសាមណេរជាបេក្ខសមណៈដែលបានប្រឡងជាប់តាមរបៀបខាងលើនេះហើយនឹងត្រូវបានងារជាព្រះមហា ៣ ប្រយោគ ។

ប៉ុន្តែបើភិក្ខុដែលមានសមណៈសក្តិឋានានុក្រមនោះពុំមានងារជាមហាទេ គេហៅភិក្ខុនោះថា ឋានានុក្រមទ្រង់គ្រឿងគឺគេហៅថា វិន័យធរទ្រង់គ្រឿង ព្រះគ្រូទ្រង់គ្រឿង ព្រះបាឡាត់ទ្រង់គ្រឿង ព្រះសមុហ៍ទ្រង់គ្រឿង

កាលបើបេក្ខសមណៈ គឺភិក្ខុសាមណេរទាំងឡាយ បានប្រឡងត្រឹម ៣ ប្រយោគរួចសព្វគ្រប់ហើយ ការប្រឡងនោះត្រូវឈប់សម្រាក ៗ លំដាប់ពីនោះទៅទៀត ក្នុងបណ្តាបេក្ខសមណៈដែលបានប្រឡងជាប់ត្រឹម ៣ ប្រយោគហើយ បើមានបេក្ខសមណៈណាមានសមត្ថភាពអាចនឹងប្រឡងយកប្រយោគទី ៤ ទៀត បេក្ខសមណៈនោះត្រូវចុះឈ្មោះសូមប្រឡងតទៅទៀត ការប្រឡងយកប្រយោគទី ៤ នោះ មានរបៀបដូចជាប្រឡងយកថ្នាក់មហា ៣ ប្រយោគដែរ គឺគ្រាន់តែប្រែពីបាលីជាខ្មែរប៉ុណ្ណោះឯង ឥតមានបន្ថែមវិជ្ជាអ្វីផ្សេងទៀតទេ ដែលប្លែកតែត្រង់អត្ថបទប៉ុណ្ណោះ អត្ថបទក្នុងប្រយោគទី ៤ នោះគឺដកស្រង់យកពីគម្ពីរមង្គលត្ថទីបនី ជាអដ្ឋកថាមង្គលសូត្រ, បេក្ខសមណៈណាបានប្រឡងជាប់ បេក្ខណៈនោះអាចទទួលឋានៈជាមហា ៤ ប្រយោគ ។

តាមរបៀបនៃការប្រឡង (ដេញប្រយោគ) នេះត្រូវមានតាំងពីថ្នាក់ ៣ ប្រយោគដល់ថ្នាក់ ៩ ប្រយោគ ប៉ុន្តែក្នុងប្រទេសកម្ពុជា កាលពីក្នុងសម័យព្រេងនាយប្រហែលជាមានដល់ថ្នាក់ ៩ ប្រយោគដែរ លុះចំណេរកាលតមក ដល់មកក្នុងរជ្ជកាលសម័យយើងកើតទាន់មានត្រឹមតែថ្នាក់ ៥ ប្រយោគនឹង ៦ ប្រយោគប៉ុណ្ណោះ ។

## ការតែងតាំងឋានន្តរជាមហា

ការតែងតាំងនោះ គឺព្រះករុណាជាអម្ចាស់ជីវិតទ្រង់តែងតាំងផ្ទាល់ព្រះអង្គ ប៉ុន្តែឥតប្រគេនសញ្ញាប័ត្រដូចសព្វថ្ងៃនេះទេ ទ្រង់គ្រាន់តែប្រគេនផ្ចិត ៗ នោះ ប្លែកអំពីផ្ចិតព្រះរាជាគណៈឋានានុក្រមគឺជាផ្ចិតមួយដោយឡែកសម្រាប់ភិក្ខុសាមណេរដែលប្រឡងជាប់បានឋានៈជាទីមហា ៗ ផ្ចិតសម្រាប់មហា ៣ ប្រយោគមានសណ្ឋានផ្សេងពីផ្ចិតសម្រាប់មហា ៤ ប្រយោគ ៗ

ឋានៈជាមហានោះ មានកិត្តិគុណកិត្តិសព្ទជាងបព្វជិតដែលមិនមានប្រយោគ ៗ ក្រៅអំពីផ្ចិតព្រះករុណាទ្រង់ប្រោសព្រះរាជទានគ្រឿងបរិក្ខារផ្សេង ៗ មានត្រៃចីវរជាដើមថែមទៀត ។

## សេចក្តីបញ្ជាក់ពិសេស

ការសិក្សាខាងព្រះពុទ្ធសាសនា នឹងការប្រឡង (ដេញប្រយោគ) ដែលបានរៀបរាប់ខាងលើនេះ ខ្ញុំអ្នកនិពន្ធបានដឹងថាការប្រឡង (ដេញប្រយោគ) នោះ មានម្តងក្នុងរាជ្យព្រះករុណានរោត្តម (ព្រះសុវណ្ណកោដ្ឋ) មានម្តងទៀតក្នុងរាជ្យព្រះករុណាស៊ីសុវត្ថិ (ព្រះរាជានុកោដ្ឋ) តែ ២ ដងប៉ុណ្ណោះ ។ ឯចំពោះការសិក្សានោះបានដឹងថា កាលក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សរាមា ព្រះអង្គដួង (ព្រះបរមកោដ្ឋ) ក៏មានការសិក្សាដែរ តែត្រង់ការប្រឡង (ដេញប្រយោគ) មិនមានដំណឹងថាបានធ្វើទេ ដោយក្នុងសម័យនោះ អ្នកសិក្សាព្រះបរិយត្តិធម៌ មានចំនួនតិចតួចពេក ៗ ប៉ុន្តែចំពោះព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សរាមា ព្រះអង្គទ្រង់ជ្រាបវិជ្ជាប្រែបាលីតាមដំណឹងថាព្រះអង្គបានតាំងបង្ហាត់បង្រៀនប្រែបាលី ដល់ភិក្ខុសាមណេរទាំងឡាយខ្លះផងទៀត តាំងសមថកម្មដ្ឋានព្រះអង្គក៏ទ្រង់ជ្រាបផងដែរ ។

# ការសិក្សាខាងព្រះពុទ្ធសាសនា សម័យកណ្ដាល

លំដាប់តពីនោះមក ការសិក្សាមានការប្រែប្រួល គឺរាជការអាណាព្យាបាលបារាំងសេស បានព្រមព្រៀងជាមួយនឹងរាជការខ្មែរ ដោយព្រះករុណាជាម្ចាស់ជីវិតព្រះបាទសម្ដេចព្រះស៊ីសុវត្ថិបានយល់ព្រមផង បានបង្កើតឲ្យមានសាលាបាលី ១ នៅនគរវត្តក្នុងខេត្តសៀមរាប តាមព្រះយោបល់នៃសម្ដេចព្រះមហាសង្ឃរាជទ្រង់ព្រះនាមទៀង ។ ការសិក្សានៅក្នុងសាលានោះពុំទាន់មានការរៀបចំកែប្រែថ្មីនៅឡើយទេ គឺនៅជារបៀបចាស់ដូចមុន គ្រាន់តែមានឈ្មោះថាសាលានោះរាជការបានរៀបចំបង្កើតឲ្យមានឡើងប៉ុណ្ណោះ ។

សាលាបាលីនៅនគរវត្តនោះ បានប្រព្រឹត្តទៅប្រមាណតែជិត ៣ ឆ្នាំប៉ុណ្ណោះ គឺពី គ.ស. ១៩០៩-១៩១១ ក៏ត្រូវរើចេញ ព្រោះសាលាបាលីដែលបង្កើតឲ្យមាននៅទីនោះ មិនអាចធ្វើដំណើរទៅកាន់វឌ្ឍនភាពបាន ដោយហេតុសាលាបាលីនៅទីនោះមិនប្រកបដោយលក្ខណសម្បត្តិគ្រប់គ្រាន់ ។

តពីនោះមក ដល់មក គ.ស. ១៩១៤ រាជការអាណាព្យាបាលនិងរាជការខ្មែរ បានព្រមព្រៀងឲ្យបង្កើតសារជាថ្មីទៀតនូវសាលាបាលីក្នុងទីវត្តព្រះកែវមរកតក្រុងភ្នំពេញជាបណ្ដោះអាសន្ន ក្រោមព្រះបរមរាជូបត្ថម្ភនៃព្រះករុណាជាម្ចាស់ជីវិត ។ គ្រឿងសម្ភារៈសម្រាប់សាលាបានរៀបចំឲ្យមានតុ: ជើងម៉ា សម្រាប់គ្រូ សម្រាប់សិស្សជារបៀបសាលារៀនតាមសម័យបច្ចុប្បន្ន ប៉ុន្តែវិជ្ជាដែលសិក្សា ក៏នៅចំពោះត្រឹមតែភាសាបាលី គឺសិក្សារៀនអំពីមូលវេយ្យាករណ៍ រហូតដល់ប្រែគម្ពីរធម្មបទដ្ឋកថា មង្គលត្ថទីបនី បឋមសមន្តបាសាទិកា វិសុទ្ធិមគ្គ និងព្រះអភិធម្មត្ថសង្គហៈ ឥតទាន់មានបញ្ចូលវិជ្ជាផ្លូវលោកឲ្យសិក្សានៅឡើយ ។ បំណែកសាស្ត្រាចារ្យជាអ្នកបង្រៀន ក៏បានជ្រើសរើសមានកំណត់ដោយការប្រឡង ទាំងសមណនិស្សិតដែលត្រូវឲ្យចូលសិក្សាក្នុងសាលាបាលីនោះ ក៏មានកំណត់ចំនួន គឺត្រូវជ្រើសរើសដោយការប្រឡងប្រជែងដែរ ។ សិស្សដែលរៀនគ្រប់កំណត់ឆ្នាំត្រូវប្រឡងចេញ បើប្រឡងជាប់ត្រូវបានសញ្ញាប័ត្រហៅថាសញ្ញាប័ត្រសាលាបាលី មានឋានន្តរជាទីមហា ។

តពីនោះមក មិនយូរប៉ុន្មានរាជការបានកសាងសាលាបាលីថ្មី ១ នៅជ្រុងផ្សារស្ដូន (ដែលសព្វថ្ងៃនេះបានរៀបចំជាមន្ទីរពុទ្ធសាសនបណ្ឌិត្យ និងក្រសួងធម្មការ) កាលដែលកសាងសាលាបាលីថ្មីនោះរួចស្រេចហើយ រាជការបានរើចេញពីវត្តព្រះកែវមរកតមករៀបចំក្នុងសាលាបាលីថ្មីនោះ បានកែប្រែឈ្មោះឲ្យខ្ពស់

បន្តិច ជាសាលាបាលីជាន់ខ្ពស់ (Ecole supérieure de pali) ។ ការសិក្សាក្នុងសាលាបាលីជាន់ខ្ពស់នាសម័យនោះ មានសភាពដូចជាសម័យបច្ចុប្បន្ននេះដែរ ប៉ុន្តែមុខវិជ្ជាសិក្សានៅជារបៀបចាស់ដដែល គឺសិក្សាតែមុខវិជ្ជាបាលីតែម្យ៉ាងប៉ុណ្ណោះ ។

លំដាប់តមក ការសិក្សាក្នុងសាលាបាលីជាន់ខ្ពស់ មានការបន្ថែមវិជ្ជាខាងភាសាបារាំងសេស ភាសាសំស្រ្កឹត តមកទៀតមានការបន្ថែមវិជ្ជាផ្លូវលោក មានគណិតសាស្រ្តនិងភូមិសាស្រ្តជាដើម ។

ការសិក្សាក្នុងសាលាបាលីជាន់ខ្ពស់ កំណត់ត្រឹម ៤ ឆ្នាំ អ្នកសិក្សាត្រូវប្រឡងចេញយកសញ្ញាបត្រសាលាបាលីជាន់ខ្ពស់ ។ បើប្រឡងជាប់ត្រូវបានសញ្ញាបត្រមានឋានន្តរជាមហាបរិយត្តិឧត្តមវិជ្ជា ។

ការបង្កើតឲ្យមានសាលាសិក្សាខាងព្រះពុទ្ធសាសនានេះ ឲ្យមានត្រឹមតែសាលា ១ ប៉ុណ្ណោះ អស់កាលជាយូរឆ្នាំ រាជការអាណាព្យាបាលបារាំងសេសនិងរដ្ឋាភិបាលយល់ឃើញថាមិនគួនល្មមដល់ចំនួនសមណ-និស្សិតដែលត្រូវការនឹងសិក្សា មានចំនួនកាន់តែច្រើនឡើង ។ ទើបបានបង្កើតឲ្យមានព្រះរាជប្រកាស ១ ក្នុងគ.ស. ១៩៣៣ អនុញ្ញាតឲ្យព្រះសង្ឃនិងពុទ្ធបរិស័ទទាំងឡាយដែលត្រូវការចង់បង្កើតឲ្យមានសាលាបាលីរងក្នុងវត្តរបស់ខ្លួនអាចសូមបង្កើតបាន រាជការនឹងទទួលស្គាល់ទុកដូចជាសាលាបាលីរងរបស់រាជការ សាលានោះតម្រូវឲ្យមានការសិក្សាកំណត់ត្រឹម ៣ ឆ្នាំ អ្នកសិក្សាត្រូវប្រឡងចេញ បេក្ខសមណៈដែលប្រឡងជាប់ត្រូវបានទទួលវិញ្ញាបនប័ត្រសាលាបាលីរង អ្នកដែលប្រឡងជាប់នេះត្រូវមានឋានន្តរជាមហាបរិយត្តិបឋមវិជ្ជា ហើយមានសិទ្ធិចូលប្រឡងប្រជែងយកកន្លែងសិក្សា ក្នុងសាលាបាលីជាន់ខ្ពស់តទៅទៀត ។

តពីនោះមកទៀត ក្នុងសម័យដែលប្រទេសកម្ពុជាបានឋានៈជាប្រទេសឯករាជ្យអព្យាក្រឹតឡើង រាជការបានបង្កើតឲ្យមានការសិក្សាខាងព្រះពុទ្ធសាសនាកាន់តែខ្ពស់ឡើង ឲ្យសមដល់កាលៈទេសៈ គឺបង្កើតឲ្យមានពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។ ឯសាលាបាលីជាន់ខ្ពស់ ក៏បានកែឈ្មោះទៅជាពុទ្ធិកវិទ្យាល័យព្រះ-សុរាម្រឹត ទាំងសាលាបាលីរងក៏បានរៀបចំកែឈ្មោះទៅជាសាលាពុទ្ធិកបឋមសិក្សាវិញ មុខវិជ្ជាសម្រាប់សិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យ ពុទ្ធិកវិទ្យាល័យ និងក្នុងពុទ្ធិកបឋមសិក្សា ក៏បានរៀបចំកែប្រែឲ្យមានកម្មវិធីល្អគួរសមខ្ពស់ជាងពីកាលជាន់មុនដ៏ច្រើនឲ្យសមដល់កាលសម័យដូចមានសេចក្តីរៀបរាប់តទៅនេះ ។

# ការសិក្សាក្នុងសម័យបច្ចុប្បន្ន

ក្នុងសម័យបច្ចុប្បន្ន គឺសម័យដែលប្រទេសកម្ពុជាបានទទួលឋានៈជាប្រទេសឯករាជ្យអព្យាក្រឹតតមក ដល់សព្វថ្ងៃនេះ ការសិក្សាខាងព្រះពុទ្ធសាសនា ដែលបានរើរៀបចំបន្តិចម្តង ៗ បានប្រព្រឹត្តទៅក្នុងដំណើរ ដ៏រៀបរយល្អ គួរឲ្យមានសេចក្តីសង្ឃឹមថាការសិក្សានោះ មានដំណើរឆ្ពោះទៅកាន់វឌ្ឍនភាពយ៉ាងប្រសើរ ។ ការសិក្សានេះយ៉ាងណាខ្លះ ខ្ញុំសូមនាំយកមកសរសេរទុកលើទំព័រនេះយ៉ាងសង្ខេបដូចតទៅនេះ ។

ការសិក្សាខាងព្រះពុទ្ធសាសនា ហៅថាពុទ្ធិកសិក្សា ។ នេះ ចែកជា ៣ ផ្នែកគឺ ពុទ្ធិកបឋមសិក្សា១ ពុទ្ធិកមធ្យមសិក្សា ១ ពុទ្ធិកឧត្តមសិក្សា ១ ។

## ពុទ្ធិកបឋមសិក្សា

ការសិក្សាដំបូងនូវវិជ្ជាផ្សេង ៗ រួបរួមជាមួយនឹងវិជ្ជាខាងព្រះពុទ្ធសាសនា ហៅថាពុទ្ធិកបឋមសិក្សា ។ ពុទ្ធិកបឋមសិក្សាមាននៅតាមវត្តអារាមក្នុងក្រុង នឹង ក្នុងខេត្តទាំងអស់ សព្វថ្ងៃនេះបើរួបរួមទៅមានសាលាពុទ្ធិកបឋមសិក្សាចំនួន ៥៧០ សាលា ។ អ្នកសិក្សាមានតែភិក្ខុសាមណេរជាអ្នកសិក្សា យុវជនជាគ្រហស្ថ មិនមានទេ ។

មុខវិជ្ជាដែលត្រូវសិក្សាក្នុងសាលាពុទ្ធិកបឋមសិក្សា មានទាំងខាងផ្នែកវិជ្ជាខាងព្រះពុទ្ធសាសនា មានទាំងខាងវិជ្ជាផ្លូវលោក

## មុខវិជ្ជាខាងព្រះពុទ្ធសាសនាគឺ :

១– វេយ្យាករណ៍បាលី

២– ការប្រែពីបាលីធម្មបទដ្ឋកថាមកជាភាសាខ្មែរ

៣– ពុទ្ធប្បវត្តិ

៤– ពុទ្ធសាសនា

៥– វិន័យសម្រាប់បព្វជិត

## មុខវិជ្ជាខាងផ្លូវលោកគឺ :

១– គណិតសាស្ត្រ

២– ភូមិសាស្ត្រ-ប្រវត្តិសាស្ត្រ

៣– វិទ្យាសាស្ត្រ

៤– អនាម័យ

៥– លោកនីតិ

៦– កសិកម្មសង្ខេប

សមណនិស្សិតបានសិក្សាក្នុងសាលាពុទ្ធិកបឋមសិក្សា តាមមុខវិជ្ជាខាងលើនេះ អស់កាលកំណត់ត្រឹម ៣ ឆ្នាំត្រូវប្រឡង ។ ការប្រឡងនោះ ក្រសួងធម្មការបានចាត់ចែងធ្វើក្នុងព្រះរាជអាណាចក្រទាំងមូល ដោយបែងចែកមណ្ឌលប្រឡងក្នុងទីក្រុងភ្នំពេញ និងក្នុងខេត្តទាំងអស់ ក្នុងពេលស្មើគ្នា ទាំងប្រយោគដែលដាក់ឲ្យសមណនិស្សិតប្រឡង ក៏ដូចគ្នាទាំងអស់ ។ សមណនិស្សិតណាប្រឡងជាប់ សមណនិស្សិតនោះត្រូវបានទទួលវិញ្ញាបនប័ត្រ ១ ជាគ្រឿងសំគាល់ ដែលអធិបតីនៃគណៈកម្មការនាយកចេញឲ្យ ដោយមានសេចក្តីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ ។

សមណនិស្សិត ទាំងប៉ុន្មាន ដែលបានប្រឡងជាប់ បានទទួលវិញ្ញាបនប័ត្រហើយ ត្រូវមានឋានន្តរជាមហាបរិយត្តិបឋមវិជ្ជាហើយ មានសិទ្ធិសូមចុះឈ្មោះប្រឡងប្រជែង យកកន្លែងសិក្សាក្នុងពុទ្ធិក វិទ្យាល័យព្រះ-សុរាម្រឹតតទៅទៀត ។

## ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

ការសិក្សាក្នុងពុទ្ធិកវិទ្យាល័យនេះ ហៅថា «មធ្យមសិក្សា» ព្រោះសិក្សានូវវិជ្ជាមានឋានៈជាមធ្យម ។ សព្វថ្ងៃនេះពុទ្ធិកវិទ្យាល័យមានតែ ១ នៅក្រុងភ្នំពេញ ។ ពុទ្ធិកវិទ្យាល័យនេះ បានជ្រើសរើសក្នុងបណ្តាសមណនិស្សិតទាំងឡាយដែលមានវិញ្ញាបនប័ត្រ ដោយឲ្យប្រឡងប្រជែងក្នុង ១ ឆ្នាំ ១ យកសមណនិស្សិតចំនួន ១៥០ រូបឲ្យចូលមកសិក្សា ។ ការសិក្សាក្នុងពុទ្ធិកវិទ្យាល័យនេះ មានកាលកំណត់ត្រឹម ៤ ឆ្នាំ ។

រីឯមុខវិជ្ជាដែលត្រូវសិក្សាក្នុងពុទ្ធិកវិទ្យាល័យ មានទាំងវិជ្ជាខាងព្រះពុទ្ធសាសនា ទឹងខាងផ្លូវលោកច្រើនជាន់ទឹង ខ្ពស់ជាង ដូចតទៅនេះគឺ :

១ – ភាសាបាលី

២ – ភាសាសំស្ក្រឹត

៣ – ភាសាខ្មែរ

៤ – ភាសាបារាំងសេស

៥ – ភាសាអង់គ្លេស

៦ – ប្រវត្តិសាស្ត្រ - ភូមិសាស្ត្រ

៧ – គណិតសាស្ត្រ

៨ – វិទ្យាសាស្ត្រ = វិទ្យាសាស្ត្រធម្មជាតិ នឹងអនាម័យ, វិទ្យាសាស្ត្ររូបនិយម គីមី

៩ – វិជ្ជាទូទៅ = លោកនីតិ, ប្រវត្តិសាសនា, អរិយធម៌ខ្មែរ (សិល្បៈខ្មែរ)

សមណនិស្សិតទាំងឡាយ ដែលបានសិក្សាមុខវិជ្ជាដូចខាងលើនេះ គ្រប់កំណត់ ៤ ឆ្នាំ ហើយ ត្រូវប្រឡង ។ សមណនិស្សិតដែលបានប្រឡងជាប់ ត្រូវបានទទួលសញ្ញាប័ត្រមធ្យមសិក្សា ហើយត្រូវមានឋានន្តរជាមហាបរិយត្តិមធ្យមវិទ្យា ហើយមានសិទ្ធិសូមចូលសិក្សា ក្នុងពុទ្ធិកមហាវិទ្យាល័យតទៅទៀតបាន ។

## ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ពុទ្ធិកមហាវិទ្យាល័យនេះ បានជ្រើសរើសយកក្នុងបណ្ដាសមណនិស្សិតដែលមានសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា ហើយដែលបានធ្វើលិខិតសូមផងក្នុង ១ ឆ្នាំយកត្រឹមតែចំនួន ៤០ រូប តាមលំដាប់លេខរៀងដែលបានប្រឡងជាប់ ។ ការសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យនេះ ជាឧត្តមសិក្សា ចែកជា ៣ ភូមិគឺ :

១ – ឧត្តមសិក្សាបឋមភូមិ ការសិក្សានូវវិជ្ជាដ៏ខ្ពស់ជាងមធ្យមសិក្សា កំណត់កាលសិក្សាត្រឹម ៣ ឆ្នាំ

២ – ឧត្តមសិក្សាទុតិយភូមិ ការសិក្សានូវវិជ្ជាខ្ពង់ខ្ពស់ កំណត់កាលសិក្សាត្រឹម ៤ ឆ្នាំ

៣ – ឧត្តមសិក្សាតតិយភូមិ ការសិក្សានូវវិជ្ជាខ្ពង់ខ្ពស់បំផុតកំណត់កាលសិក្សាត្រឹម ៣ ឆ្នាំ

រួមកាលសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យ មានកំណត់កាលត្រឹម ១០ ឆ្នាំគត់ ។

ការសិក្សាទាំង ៣ ភូមិខាងលើនេះ បើរួបរួមកាលសិក្សាឃើញថាមានដល់ ១០ ឆ្នាំ ក៏ពិតមែនហើយ ប៉ុន្តែពុំបានដាក់កំរិតតម្រូវឲ្យសិក្សាដល់ ១០ ឆ្នាំ ទើបបាននោះទេ ។ បើសមណនិស្សិតណាសិក្សាបានតែ ៣ ឆ្នាំ ហើយពុំអាចបន្តការសិក្សាទៅមុខទៀតក៏បាន ឬក៏អាចសិក្សាបន្តទៅទៀតក៏បាន ស្រេចហើយតែនឹងសមត្ថភាពរបស់សមណនិស្សិត ។

រីឯមុខវិជ្ជាដែលត្រូវសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យខាងផ្នែកបឋមភូមិត្រឹម ៣ ឆ្នាំនោះ ដូចតទៅនេះ

១– សាសនា គឺប្រវត្តិនៃព្រះពុទ្ធសាសនា

សាសនាប្រៀបធៀប

លទ្ធិព្រះពុទ្ធសាសនា

ការអប់រំចិត្តតាមគន្លងព្រះពុទ្ធសាសនា (សមាធិ)

២– ទស្សនវិជ្ជា គឺចិត្តសាស្ត្រ ឬ ចិត្តវិជ្ជា

– សង្គមសាស្ត្រ ឬ សង្គមវិជ្ជា

– តក្កសាស្ត្រ ឬ តក្កវិជ្ជា

– សីលធម៌

– ទស្សនវិជ្ជាទូទៅ នឹង ទស្សនវិជ្ជា ប្រៀបធៀប

៣– ភាសាបាលី

៤– ភាសាសំស្ក្រឹត

៥– ជីវភាសាខាងបុរត្ថិមទិស គឺភាសាចិន ឬ ហិណ្ឌី ឬ ថៃ

៦– ជីវភាសាខាងបច្ចិមទិស គឺភាសាបារាំងសេស ឬ អង់គ្លេស

៧– ប្រវត្តិសាស្ត្រ ⎫ ខាងបស្ចិមនឹងបុរត្ថិមទិស
៨– ភូមិសាស្ត្រ ⎭

៩– គណិតសាស្ត្រ

១០– វិទ្យាសាស្ត្របឋមនិយម

១១– វិទ្យាសាស្ត្រធម្មជាតិ ( ព្រឹក្សសាស្ត្រ , សត្វសាស្ត្រ , សរីរវិទ្យា , អាកាសវិទ្យា )

១២– គីមី

១៣– វិជ្ជាទូទៅគឺ អនាម័យ នឹងវិជ្ជាពេទ្យសង្ខេប

– លោកនីតិ នឹងអរិយធម៌

– ការអប់រំ ( វិជ្ជាគរុកោសល្យ ទូទៅ )

– បគ្រាក់ឡូវិទ្យា

សមណនិស្សិតកាលបើបានសិក្សានូវមុខវិជ្ជាក្នុងបឋមភូមិដូចខាងលើនេះ គ្រប់កំណត់ ៣ ឆ្នាំហើយ ត្រូវប្រឡង ។ សមណនិស្សិតណាដែលបានប្រឡងជាប់ សមណនិស្សិតនោះត្រូវទទួលសញ្ញាប័ត្រឧត្តមសិក្សាថ្នាក់បឋមភូមិ សញ្ញាប័ត្រនេះស្មើគានឹង (Baccaloréat) ។

សមណនិស្សិតដែលបានទទួលសញ្ញាប័ត្រឧត្តមសិក្សា ថ្នាក់បឋមភូមិហើយ អាចនឹងសូមចូលទៅសិក្សាក្នុងឧត្តមសិក្សាទុតិយភូមិបាន, ការសិក្សាក្នុងឧត្តមសិក្សាទុតិយភូមិនោះ មានការសិក្សាកំណត់ ៤ ឆ្នាំ ។ រីឯមុខវិជ្ជាដែលត្រូវសិក្សានោះដូចតទៅនេះ

ក ) មុខវិជ្ជាជាកាតព្វកិច្ច តាមវិជ្ជាជាឯកទេសនៃបរិញ្ញាប័ត្រ

លទ្ធិពុទ្ធសាសនា

– ទស្សនវិជ្ជា

– ភាសាសាស្ត្រ

– ភាសាប្រចាំថ្នាក់ ឬភាសាបុរាណ= បាលី , សំស្ក្រឹត

– ជីវភាសា

– អារ្យធម៌ខ្មែរ

ខ ) មុខវិជ្ជាដែលត្រូវរៀនតាមស្ម័គ្រ

ថ្នាក់ឆ្នាំ ទី ១ - ២ - ៣ - ៤ ( គ្រប់វិជ្ជាជាឯកទេសសម្រាប់បរិញ្ញាប័ត្រ )

– ច្បាប់ : រដ្ឋធម្មនុញ្ញ , រដ្ឋប្បវេណី ( ស៊ីវិល ) រដ្ឋបាលព្រហ្មទណ្ឌ , ច្បាប់អន្តរជាតិ សាធារណៈ

– វិទ្យាសាស្ត្រ

– ប្រវត្តិសាស្ត្រ នឹងភូមិសាស្ត្រ

– វត្ថុធាតុនៃបច្រកព្យវិទ្យា

– សេដ្ឋកិច្ចនយោបាយ នឹងការរៀបចំរដ្ឋ

– ជាតិពន្ធុវិទ្យា

– សិល្បសាស្ត្រ

– អាចរិយវិទ្យា - ការអប់រំ

រីឯការសិក្សាជាន់ខ្ពស់ ថ្នាក់ទុតិយភូមិនោះ អាចបើកសិទ្ធិឲ្យសមណនិស្សិតបានទទួលនូវវិញ្ញាបនប័ត្រ១

ជាចំមុខដែលមាននាមថាទៅជា « បរិញ្ញាប័ត្រមហាវិទ្យាល័យព្រះពុទ្ធសាសនា »

## ១– បរិញ្ញាប័ត្រការសិក្សាលទ្ធិសាសនា

១– វិញ្ញាបនប័ត្រ លទ្ធិព្រះពុទ្ធសាសនា

២– " ពុទ្ធប្បវត្តិ

៣– " ទស្សនវិជ្ជាប្រៀបធៀប

៤– " លទ្ធិសាសនា ប្រៀបធៀប

## ២– បរិញ្ញាប័ត្រទស្សនវិជ្ជាប្រៀបធៀប

១– វិញ្ញាបនប័ត្រ ទស្សនវិជ្ជាទូទៅ

២– " ទស្សនវិជ្ជាបស្ចិមទិស

៣– " ទស្សនវិជ្ជាបុរត្ថិមទិស

៤– " លទ្ធិសាសនាប្រៀបធៀប

## ៣- បរិញ្ញាប័ត្រភាសាសាស្ត្រ

១– វិញ្ញាបនប័ត្រ សព្ទសាស្ត្រទូទៅ

២– „ សព្ទវិទ្យា ( Phonologie )

៣– „ ភាសាសាស្ត្រទូទៅ

៤– „ លទ្ធិសាសនាប្រៀបធៀប

## ៤- បរិញ្ញាប័ត្រអារ្យធម៌ខ្មែរ

១– វិញ្ញាបនប័ត្រ ភាសាសាស្ត្រទូទៅ

២– „ អារ្យធម៌ខ្មែរ ( អក្សរសាស្ត្រនិងសិល្បៈ )

៣– „ អារ្យធម៌ប្រៀបធៀប

៤– „ លទ្ធិសាសនាប្រៀបធៀប

## ៥- បរិញ្ញាប័ត្រភាសាប្រចាំថ្នាក់ឬភាសាបូរាណ

១– វិញ្ញាបនប័ត្រ បាលី

២– „ សំស្ក្រឹត

៣– „ ភាសាសាស្ត្រទូទៅ

៤– „ លទ្ធិសាសនាប្រៀបធៀប

## ៦- បរិញ្ញាប័ត្រជីវភាសា

១– វិញ្ញាបនប័ត្រ ភាសាអង់គ្លេស ឬ បារាំង ( ភាសាបស្ចិមទិសណាមួយ )

២– „ ភាសាហិណ្ឌូឬសៀម ( ភាសាបុរត្ថិមទិសណាមួយ )

៣ – " ភាសាសាស្ត្រទូទៅ

៤ – " លទ្ធិសាសនាប្រៀបធៀប

សមណនិស្សិតទាំងឡាយណា ដែលបានទទួលបរិញ្ញាប័ត្រណាមួយហើយ សមណនិស្សិតទាំងឡាយនោះ នឹងអាចសូមបន្តការសិក្សាទៅក្នុងឧត្តមសិក្សាតតិយភូមិទៀតបាន ។ រយៈកាលសិក្សាក្នុងឧត្តម-សិក្សាជាន់ទី ៣ នេះ មានកំណត់ត្រឹម ៣ ឆ្នាំ ។ សមណនិស្សិតដែលបានសិក្សាចប់ហើយ ត្រូវបានទទួលឋានន្តរស័ក្តិជាបណ្ឌិតមហាវិទ្យាល័យពុទ្ធសាសនា ក្រោយដែលបាននិពន្ធរឿងរ៉ាវណាមួយបោះពុម្ព ហើយរឿងដែលបោះពុម្ពនោះគេបានពិនិត្យ ហើយប្រកាសថាត្រឹមត្រូវ គួរល្មមដល់ការទទួលឋានន្តរស័ក្តិជាបណ្ឌិត ៕

## ហេតុដែលនាំឲ្យមានការរៀបចំការសិក្សា

ក្រោយដែលប្រទេសកម្ពុជាបានទទួលឋានៈជាប្រទេសឯករាជ្យហើយ ព្រះករុណាជាអម្ចាស់ជីវិតព្រះបាទសម្តេចព្រះនរោត្តម-សីហនុវរ្ម័នព្រះចៅព្រះរាជអាណាចក្រកម្ពុជា ទ្រង់មានព្រះវិចារណញ្ញាណយល់ឃើញថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា ដែលជាពុទ្ធសាសនិកមានចំនួន ៩៩ ភាគរយ ព្រះសង្ឃក្នុងប្រទេសកម្ពុជា តាំងពីបុរាណកាលមកជាគ្រូបាអាចារ្យបង្ហាត់បង្រៀនកុលបុត្រជាកូនចៅនៃប្រជាពលរដ្ឋទាំងអស់ ព្រោះក្នុងសម័យមុនវត្តអារាមដែលព្រះសង្ឃគង់នៅ ជាកន្លែងសិក្សារៀនសូត្ររបស់ប្រជាពលរដ្ឋឥតមានសាលារៀនក្រៅពីវត្តអារាមទេ ម្ល៉ោះហើយប្រជាពលរដ្ឋទាំងអស់ បានកំណត់ទុកក្នុងចិត្តយកវត្តអារាមជាកន្លែងសិក្សា យកព្រះសង្ឃជាគ្រូបាអាចារ្យ ហើយគោរពបូជាចំពោះព្រះសង្ឃជានិច្ចរាបតមក ។

ព្រះពុទ្ធសាសនាដែលមាននៅក្នុងប្រទេសកម្ពុជា ជាច្រើនសតវត្សរ៍មកហើយ មិនខ្វាត់ខ្វាយសាបរលាបបាត់បង់ទៅ ហើយចេះតែឋិតនៅយ៉ាងរុងរឿងតមក ក៏ដោយអាស្រ័យព្រះសង្ឃជាអ្នកណែនាំប្រជាពលរដ្ឋឲ្យចេះដឹងច្បាប់ព្រះពុទ្ធសាសនា ទាំងប្រជាពលរដ្ឋក៏ចេះគោរពកោតអានបូជាចំពោះព្រះសង្ឃវិញ ។ ព្រះសង្ឃនឹងគ្រហស្ថ មានការប្រាស្រ័យគ្នាទៅវិញទៅមកក្នុងឋានៈដ៏មានតម្លៃ ។

ក្នុងសម័យបច្ចុប្បន្ននេះ កុលបុត្រជាកូនចៅប្រជាពលរដ្ឋសិក្សារៀនសូត្រ ក្នុងសាលារៀនរបស់រាជការច្រើនតែពុំសូវមានការពាក់ទងទៅរកព្រះសង្ឃក្នុងវត្តអារាមដូចសម័យមុនទៀតឡើយ ។ សម្តេចព្រះនរោត្តម-សីហនុទ្រង់ឈ្វេងយល់ថាតទៅក្នុងអនាគត ប្រសិនបើប្រជាពលរដ្ឋមានការចេះដឹងច្រើនឡើងតាមសម័យនិយម

ហើយឥតមានការរៀនសូត្រពីសំណាក់ព្រះសង្ឃទេ ដរាបណាដរាបនោះប្រជាពលរដ្ឋនឹងអស់សេចក្ដីគោរពរាប់អានចំពោះទៅរកព្រះសង្ឃ ។ ចំណែកព្រះសង្ឃដែលធ្លាប់តែបង្ហាត់បង្រៀនចំណេះវិជ្ជាផ្សេងៗ មានអក្សរជាតិជាដើមដល់គ្រហស្ថនោះ ក៏ត្រឡប់ជាអ្នកមិនមានសមត្ថភាពនឹងបង្ហាត់បង្រៀនទៅវិញ ដោយហេតុមិនមានសាលារៀនសម្រាប់ព្រះសង្ឃ ។ កាលបើព្រះសង្ឃឥតមានសាលារៀនឥតមានការសិក្សាទេ ឬក៏មានខ្លះដែរ ប៉ុន្តែមានយ៉ាងអន់ថយ ពុំស្មើនឹងសាលារៀនខាងគ្រហស្ថក៏ជាហេតុនាំឲ្យអន់ថយ ខ្សោយការចេះដឹងគឺថាតទៅមុខទៀត ព្រះសង្ឃកាន់តែល្ងង់ គ្រហស្ថកាន់តែចេះច្រើនឡើង ម៉្លោះហើយគ្រហស្ថដែលធ្លាប់តែគោរពព្រះ-សង្ឃនឹងត្រឡប់ជាមើលងាយព្រះសង្ឃទៅវិញ ព្រោះព្រះសង្ឃល្ងង់ជាង ។

កាលបើដូច្នេះ ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជានឹងត្រូវសាបរលាបតាមលំដាប់កាល រហូតដល់រលាយរលត់អស់ពន្លឺរស្មីនៅសល់តែឈ្មោះ ។

ដើម្បីញុំាងព្រះសង្ឃឲ្យមានការចេះដឹងចំណេះវិជ្ជាប្រសើរខ្ពង់ខ្ពស់ឡើង កុំឲ្យអន់ថយជាងគ្រហស្ថនោះ គួរតែបង្កើតឲ្យមានសាលារៀនខាងព្រះពុទ្ធសាសនាឲ្យមានការសិក្សាខ្ពង់ខ្ពស់ឡើង ទើបព្រះសង្ឃក្នុងប្រទេសកម្ពុជា តាំងពីក្នុងបច្ចុប្បន្ននេះតទៅក្នុងអនាគតនឹងបានទៅជាព្រះសង្ឃដ៏ឧត្ដមប្រសើរថ្លៃថ្លា ដោយការចេះដឹងភ្លឺស្វាងឥតមានអ្នកណានឹងមើលងាយបាន ទោះបីមានលោកអ្នកចេះមិនគ្រប់រូបក៏ដោយ គង់អាចយោងគ្នាឲ្យជាបព្វជិតមានតម្លៃគួរជាទីគោរព ។ ព្រះសង្ឃទាំងនេះហើយ ដែលអាចនឹងជួយជ្រោមជ្រែងព្រះពុទ្ធសាសនាឲ្យគង់នៅតទៅក្នុងអនាគត ។

ព្រះបាទសម្ដេចព្រះនរោត្ដម-សីហនុវរ្ម័ន ទ្រង់ឈ្វេងយល់ដូចខាងលើនេះទើបទ្រង់មានព្រះរាជបញ្ជាឲ្យចាត់ការរៀបចំការសិក្សាខាងព្រះពុទ្ធសាសនាឲ្យមានរបៀបរបបរៀបរយល្អឡើង ដូចដែលបានពោលខាងដើមរួចមកហើយ ។

## សាលាធម៌វិន័យ

ក្រៅពីពុទ្ធិកបឋមសិក្សា, ពុទ្ធិកមធ្យមសិក្សានិងឧត្ដមសិក្សា មានការសិក្សា ១ បែបទៀត គឺសិក្សាធម៌វិន័យ ។ សាលាសិក្សាធម៌វិន័យនេះ កើតឡើងក្នុងរជ្ជសម័យនៃព្រះករុណា ព្រះបាទសម្ដេចព្រះនរោត្ដម-សីហនុវរ្ម័នដែរ ។ សាលានេះបង្កើតឲ្យមានគ្រប់វត្តអារាមក្នុងព្រះរាជាណាចក្រកម្ពុជាជាសាលាសាធារណៈ សម្រាប់ភិក្ខុសាមណេរគ្រប់រូបដែលបួសក្នុងព្រះពុទ្ធសាសនា ហើយត្រូវតែសិក្សា ។ ភិក្ខុសាមណេរដែល

បានសិក្សាធម៌វិន័យ ហើយត្រូវប្រឡងយកវិញ្ញាបនប័ត្រធម៌វិន័យរាល់ឆ្នាំ ។ ការសិក្សាធម៌វិន័យនេះមាន ៣ ថ្នាក់ គឺថ្នាក់ឆ្នាំទី ១ ហៅថ្នាក់ត្រី ។ ថ្នាក់ឆ្នាំទី ២ ហៅថ្នាក់ទោ ។ ថ្នាក់ឆ្នាំទី ៣ ហៅថ្នាក់ ឯក ។ បព្វជិតដែលប្រឡងជាប់ ត្រូវបានវិញ្ញាបនប័ត្រតាមលំដាប់ថ្នាក់ហៅថា វិញ្ញាបនប័ត្រថ្នាក់ ត្រី - ទោ - ឯក ។ អ្នកប្រឡងជាប់នោះ មានឋានន្តរជាធម្មកោសល ត្រី - ទោ - ឯក ។

បើគ្រហស្ថ បុរសស្ត្រី ដែលមានព្យាយាមបានយកច្បាប់រៀនធម៌វិន័យ ទៅសិក្សាឯផ្ទះសំនៅរបស់ខ្លួន ហើយបានប្រឡងជាប់បានទទួលវិញ្ញាបនប័ត្រដែរ ត្រូវមានឋានន្តរជាធម្មវិទូ ត្រី - ទោ - ឯក ។

វិញ្ញាបនប័ត្រធម៌វិន័យនេះ មានកិត្តិគុណត្រឹមតែជាតម្លៃនៃពុទ្ធសាសនិកជនក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។ ការប្រឡងធម៌វិន័យនោះ ចាត់ចែងធ្វើដោយក្រសួងធម្មការ ជាកិច្ចទាក់ទងនឹងសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ។

ចប់ដោយសង្ខេបត្រឹមប៉ុណ្ណោះ

ព្រះពោធិវង្ស ហ.គ. វជិរប្បញ្ញោ

អគ្គាធិការនៃពុទ្ធិកសិក្សា

## Condensé en français de l'Article en langue cambodgienne de Préah Bodhivamsa (Huot-Tath) sur l'Enseignement bouddhique au Cambodge dans le passé et en temps présent par ( Ray-Lomuth )

Dans le passé, l'Enseignement bouddhique ou en d'autres termes, l'Enseignement du Tripitaka au Cambodge se faisait uniquement dans les pagodes, sans aucune commodité, ni table, ni chaise, ni tableau. Maîtres et élèves se tenaient assis sur une natte. C'était un enseignement verbal; l'élève devait savoir réciter par cœur et comprendre tout ce que lui était dit par le maître. Ainsi demandait-il de longues années d'études.

L'Enseignement n'était soumis à aucune règle pédagogique, n'avait entre autres documents que des livres en feuille de latanier et ne recevait aucune aide du Gouvernement. C'était ainsi que les maîtres et élèves étaient en nombre relativement restreint. Très peu d'élèves avaient pû poursuivre leurs études jusqu'à la fin.

Les bonzes etudiants qui savaient faire la traduction du Pali en Khmer étaient considérés comme érudits et savants.

Par la suite, Sa Majesté le Roi du Cambodge en tant que Premier Protecteur de la Religion du Bouddha accordait, à chacun des étudiants du Tripitaka de toutes les pagodes de la ville de Phnom-Penh, une prime mensuelle de trente cents (0j30) dite indemnité de pétrole à titre d'encouragement. SA Majesté avait, en outre, aménagé un emplacement réservé aux érudits en Tripitaka qui constituaient un corps de professeurs. Mais cette initiative n'encourageait guère cet Enseignement. Toutefois bon nombre de laïcs s'occupaient de cet Enseignement purement à titre privé.

### DU JURY D'EXAMEN

De temps à autres, sous la Haute Tutelle de SA Majesté le Roi, sur la proposition de l'Ordre des bonzes, le Conseil des Ministres organisait un Examen qui ne comportait pas d'épreuve écrite. L'unique épreuve orale portait sur la traduction de certaines phrases du Pali en Khmer. Bref, l'étudiant qui, devant un jury d'examen très sévère, pouvait traduire trois textes consécutifs, était déclaré admissible et recevait le Titre de «Préah Maha bey prayouk » marquant ainsi la fin du premier Stade. Les Préah Maha bey prayouk pouvaient se présenter à l'examen pour l'obtention du Titre de Préah Maha buon prayouk et comportant les mêmes épreuves de traduction mais du degré plus difficile.

Les lauréats de Préah Maha bey prayouk ou de Préah Maha boun prayouk recevaient chacun directement de Sa Majesté le Roi, en sus des équipements religieux divers, un éventail spécial. L'éventail conféré à Préah Maha buon prayouk avait le fond un peu différent de celui attribué à Préah Maha bey prayouk.

A titre de mémoire, l'examen dit plus haut avait eu lieu une fois sous le Règne de Sa Majesté Norodom, puis une autre fois sous Sa Majesté Sisowath, pourtant l'Enseignement du Pali existait depuis le Règne de Sa Majesté Angduong qui en était un Erudit et enseignait Lui-même aux bonzes et le Pali et la psychologie (Samadhi).

### LE MOYEN-AGE DE L'ENSEIGNEMENT BOUDDHIQUE

Sous le régime du Protectorat, d'accord avec le Gouvernement Khmer sous le Haut Avis favorable de Sa Majesté Sisowath, l'Administration française a procédé à quelques réformes sur l'Enseignement bouddhique au Cambodge : une école de Pali a été créée à Nokorvat (province de Siemréap ) conformément à l'avis de Samdech Sangraj (Chef des bonzes) du nom de Tieng. En

fait, cette école n'existait que de nom le régime de l'Enseignement n'ayant subi aucun changement. L'école fonctionnait en 1909 et avait dû être supprimée en 1911.

En 1914, l'Administration française et le Gouvernement Khmer s'étaient mis d'accord sur la création d'une Ecole de Pali dont le Siège social provisoire se trouvait dans l'enceinte de la pagode Préah Kèo Markât à Phnom-Penh sous la Haute Tutelle de Sa Majesté Sisowath.

Le programme d'études de cette Ecole n'avait pas changé, mais maîtres et élèves étaient choisis par voie de concours. Les étudiants ayant subi avec succès l'examen de fin d'études recevait un diplome du degré de Maha.

Peu de temps après, le Gouvernement Royal a construit une nouvelle école de Pali à côté de l'ex phsar Suon (emplacement actuel de l'Institut bouddhique et du Ministère des Cultes) où avait été transférée l'École provisoire ci-dessus. La nouvelle école fut dénommée «Ecole supérieure de Pali». Le programme d'études de 4 ans comportait en sus de la langue Pali, le français, le sanskrit, le mathématique, la géographie. Les diplomés de cette école portaient le titre de Maha Pariyat oddhama Vija.

Ce fut à partir de 1933 date de la promulgation d'un Prakas portant liberté aux bonzes et laïcs de créer des Ecoles de Pali dans le Royaume que l'Enseignement bouddhique a pris un développement considérable. Ces Ecoles ont été, par la suite, reconnues par l'Administration sous le titre de «Ecoles de Pali annexes» qui relèvent directement de l'Ecole supérieure de Pali de Phnom Penh.

Depuis l'ascension du Cambodge à l'indépendance (1953), particulièrement depuis l'avénement du Sangkum Reastr Niyum (Communauté Socialiste) (1955), l'Enseignement Bouddhique a poussé à un degré digne d'éloges : les écoles de Pali annexes et l'Ecole supérieure de Pali ont été transformées respectivement en Ecole Bouddhique de 1er cycle et en Lycée bouddhique Préah Suramarith; l'Université Préah Sihanouk Raj a été créée.

L'Enseignement est actuellement divisé en trois cycles : cycle primaire, cycle secondaire et cycle supérieur comportant chacun le programme d'études ci-dessous :

## CYCLE PRIMAIRE (3 ANS D'ÉTUDES)

### MATIÈRES D'ÉTUDES RELIGIEUSES :

— Grammaire en Pali,
— Traduction des textes Pali en Khmer,
— Histoire du Bouddhisme,
— Le Bouddhisme,
— Discipline des Bhikhu.

### MATIÈRES D'ÉTUDES GÉNÉRALES

— Mathématiques,
— Géographie - Histoire,
— Sciences,
— Instruction civique,
— Agriculture.

## CYCLE SECONDAIRE (4 ANS D'ÉTUDES)

Les étudiants de ce cycle sont choisis par voie de concours parmi les diplomés du 1er cycle.

## MATIÈRES D'ÉTUDES

1— Langue Pali,
2— Langue Sanskrit,
3— Langue Khmère,
4— Langue Française,
5— Langue Anglaise,
6— Histoire - Géographie,
7— Mathématiques,
8— Sciences : science naturelle, hygiène, physique, chimie,
9— Cultures générales : instruction civique, histoire du Bouddhisme, civilisation Khmère, (Arts Khmers).

Les diplomés de ce cycle peuvent demander leur admission à l'Université Bouddhique Préah Sihanouk Raj.

Les études supérieures dans cette Université sont divisées en trois cycles ci-dessous :

### I— CYCLE DU 1er DEGRÉ (3 ANS D'ÉTUDES)

Comportant les matières d'études suivantes :

1— RELIGION :
— Histoire du Bouddhisme,
— Religions comparées,
— Doctrine du Bouddhisme,
— Education psychologique (Samadhi).

2— PHILOSOPHIE :
— Psychologie,
— Sociologie,
— Logique,
— Morale,
— Philosophie générale et philosophies comparées.

3— Pali,
4— Sanskrit,
5— Langues vivantes orientales : chinois, Hindi ou Thai,
6— Langues vivantes occidentales : français ou anglais,
7— Histoire )
8— Géographie ) occidentales, orientales,
9— Mathématique,
10— Physique,
11— Histoire naturelle (botanique, zoologie, anatomie et Physiologie)
12— Chimie,
13— Connaissances générales : hygiène et notions médicales, instruction civique et civilisation,
— Education (pédagogie générale)
— Cosmographie.

Les Diplomés de ce cycle équivalent aux bacheliers de l'Enseignement public.

### II— CYCLE DU 2ème DEGRÉ (4 ANS D'ÉTUDES)

a)— Matières obligatoires selon les spécialités de Licences :

— Doctrine bouddhique,
— Philosophie,
— Linguistique,
— Langues classiques ou langues antiques (Pali, Sanskrit),
— Langues vivantes,
— Civilisation Khmère,

b)— Matières à option pour les 4 années et toutes les spécialités de Licences.
— Droit (constitutionnel, civil, administratif, pénal, international public et privé),
— Sciences,
— Histoire et géographie,
— Eléments de Cosmographie,
— Économie politique,
— Éthnologie.
— Archéologie,
— Pédagogie Éducation,

L'obtention d'une Série de quatre certificats groupés ci-dessous donne droit à une licence déterminée portant le nom général de «Licence de l'Université bouddhique» :

## I— LICENCE D'ETUDES RELIGIEUSES

1— Certificat de Doctrine bouddhique,
2— Certificat d'Histoire du Bouddhisme,
3— Certificat de philosophies comparées,
4— Certificat de religions comparées.

## II— LICENCE DE PHILOSOPHIES COMPARÉES

1— Certificat de philosophie générale,
2— Certificat de philosophie occidentale,
3— Certificat de philosophie orientale,
4— Certificat de religions comparées.

## III— LICENCE DE LINGUISTIQUE

1— Certificat de phonétique générale,
2— Certificat de phonologie,
3— Certificat de linguistique générale,
4— Certificat de religions comparées.

## IV— LICENCE DE CIVILISATION KHMÈRE

1— Certificat de linguistique générale,
2— Certificat de civilisation Khmère (littérature, arts)
3— Certificat de civilisations comparées,
4— Certificat de religions comparées,

## V— LICENCE DE LANGUES CLASSIQUES

1— Certificat de Pali,

2— Certificat de Sanskrit,
3— Certificat de linguistique générale,
4— Certificat de religions comparées.

## VI— LICENCE DE LANGUES VIVANTES

1— Certificat d'anglais ou de français (une langue occidentale),
2— Certificat de Hindi ou Thailandais (une langue orientale),
3— Certificat de linguistique générale,
4— Certificat de religions comparées.

Les titulaires du Diplome d'études supérieures du Second degré peuvent être accessibles au cycle d'études supérieures de degré final dont la durée est fixée à 3 ans au moins.

Le grade de Docteur de l'Université bouddhique est conféré aux candidats qui en sont déclarés dignes après la soutenance d'une thèse imprimée.

## LES RAISONS DE CETTE RÉORGANISATION DE L'ENSEIGNEMENT BOUDDHIQUE

Après l'accession du Cambodge à l'indépendance, Sa majesté Norodom Sihanouk Varman Roi du Cambodge s'est rendue compte à temps de la nécessité de cette réorganisation, étant consciente de ce que :

— la Religion bouddhique est bien la Religion de l'État,
— 99 °/₀ de la population sont bouddhistes,
— depuis la nuit des temps, les bonzes sont des instituteurs incontestés et vénérés de la masse populaire car depuis toujours la pagode c'est l'École,
— le Bouddhisme survit des époques révolues et persiste toujours digne de lui-même grace aux vénérables et éminents dirigeants bonzes,
— les liens fervents entre bonzes et population sont indestructibles et restent toujours vivants et dynamiques,
— dans le temps présent, la jeunesse estudiantine des écoles publiques méconnait de plus en plus la pagode : C'est en vue de remédier à cet état de chose et de conserver intact le prestige ancestral dans ce domaine que la réorganisation complète de l'Enseignement bouddhique telle qu'il a été exposé plus haut s'impose.

## DE L'ÉCOLE DU DHAMMA VINAYA

En dehors de l'Enseignement bouddhique exposé ci-dessus sommairement, il existe au Cambodge, une autre catégorie d'Écoles dites «École du Dhamma Vinaya» accessibles aux bonzes et laïcs. Cette catégorie d'Ecoles sont également créées sous le règne de Sa Majesté Norodom Sihanouk Varman et comportant trois cycles.

Les diplomés de cette École n'ont autre référence que celle déférant pour eux la qualité de fervents bouddhistes.

# សេចក្ដីសម្រេច

## អនុសំវច្ឆរមហាសន្និបាតទី ១៧ នៃមន្ត្រីសង្ឃគណៈមហានិកាយ

## សម្រាប់ឆ្នាំជូត ទោស័ក ព.ស. ២៥០៣

## (ពីថ្ងៃទី ១ ដល់ថ្ងៃទី ៦ មករា គ.ស. ១៩៦១)

អនុសំវច្ឆរមហាសន្និបាតទី ១៧ នៃមន្ត្រីសង្ឃគណៈមហានិកាយ សម្រាប់ឆ្នាំជូត ទោស័ក ព.ស. ២៥០៣ បានធ្វើនៅវត្តឧណ្ណាលោម ក្រោមអធិបតីភាពនៃសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ តាំងពីថ្ងៃ ១៥ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ដល់ថ្ងៃ ៥ រោច ខែឆ្នាំដដែល គឺតាំងពីថ្ងៃទី១ ដល់ថ្ងៃទី ៦ មករា ១៩៦១ ។

មន្ត្រីសង្ឃទាំងអស់គឺព្រះរាជាគណៈ ឋានានុក្រមក្នុងរាជធានីនិងលោកមេគណ - អនុគណគ្រប់ខេត្ត - គ្រប់ស្រុក ព្រមទាំងមន្ត្រីសង្ឃជាសហការីរបស់លោកមេគណ - អនុគណ ជាតំណាងព្រះសង្ឃក្នុងព្រះរាជាណាចក្រទាំងមូលបានមកជួបជុំជាមហាសន្និបាត ក្នុងព្រះបរមរាជូបត្ថម្ភនៃសម្ដេចព្រះមហាក្សត្រិយានី នឹងសម្ដេចព្រះប្រមុខរដ្ឋ ដោយរាជរដ្ឋាភិបាលដែលមានក្រសួងធម្មការជាតំណាង បានជួយចាត់ចែងឲ្យបានសម្រេចដោយប្រពៃ ។

ក្នុងរយៈពេល ៦ ថ្ងៃ ក្រោយដែលសម្ដេចព្រះសង្ឃនាយកបានបើកពេលប្រជុំហើយ ព្រះសង្ឃក្នុងមហាសន្និបាត បានពិគ្រោះគ្នា បានសន្ទនាគ្នា បានជជែកគ្នា ដោយបញ្ចេញយោបល់ផ្សេងៗ ដល់ទីបំផុតបានមូលមតិគ្នាជាឯកច្ឆន្ទចំពោះបញ្ហាទាំងឡាយដូចតទៅនេះ ៖

១– បញ្ហាគាថិងធាង មហាសន្និបាតបានយល់ស្របគ្នាចំពោះចំណុចខ្លះ ដែលធ្លាប់តែមានយោបល់ផ្សេងគ្នា ត្រូវសម្រេចឲ្យដូចគ្នាយ៉ាងនេះគឺ ៖

ក) សង្ឃត្រូវបញ្ចេញវាចាថា "សាធុ" ព្រមគ្នាក្នុងពេលដែលទាយកទាយិកា វេរកឋិនចីវរ រួចភ្លាមៗ

ខ) អាចារ្យវេរកឋិនចីវរ ត្រូវវេរ ២ ដង គឺវេរកឋិនចីវរមួយដង វេរបរិក្ខារកឋិនមួយដង តាមទំនងដែលមានក្នុងអដ្ឋកថាវិនយបិដក ។

២– បញ្ហារគាមធ្យោថាយ ទាក់ទាត់អធិការណ៍ក្នុងព្រះពុទ្ធសាសនា បញ្ហានេះមហាសន្និបាតក្រោយដែលបានបូរយោបល់គ្នាអស់កាលដ៏វែងហើយ ក៏បានសម្រេចដោយព្រមព្រៀងគ្នាជាឯកច្ឆន្ទថា ត្រូវឲ្យមានការអប់រំផង ការពិនិត្យត្រួតត្រាដោយហ្មត់ចត់របស់លោកមេគណ - អនុគណផង ការពក់ទច័

ទល់នូវអធិករណ៍ផង ដូចមានសេចក្ដីសម្រេចជាគោល ៗ តទៅនេះ ។

ក) ក្នុងវត្តនីមួយ ៗ ភិក្ខុសាមណេរទាំងឡាយ ត្រូវទទួលការអប់រំពីលោកគ្រូចៅអធិការក្នុង ១ ខែ ២ ដង ។ ការអប់រំនោះ គឺអប់រំឲ្យចេះដឹងច្បាប់វិន័យ អប់រំឲ្យមានចរិយាថ្លៃថ្នូរ អប់រំឲ្យស្គាល់តម្លៃនៃព្រះពុទ្ធ-សាសនាឲ្យច្បាស់លាស់ ។

ខ) លោកចៅអធិការគ្រប់វត្ត ត្រូវទទួលការអប់រំពីលោកអនុគណ ក្នុង ១ ឆ្នាំ ៤ ដង យ៉ាងច្រើន ២ដង យ៉ាងតិច គឺក្នុង ១ ត្រីមាសម្ដង ឬក្នុង ១ ឆមាសម្ដង តាមសមគួរដល់កាលវេលា ។ ការអប់រំនោះគឺអប់រំឲ្យលោកចៅអធិការស្រឡាញ់ការងារតាមនាទីរបស់ខ្លួនជាចៅអធិការ កុំឲ្យធ្វេសប្រហែស ។

គ) លោកមេគណ ត្រូវយកចិត្តទុកដាក់ពិនិត្យមើលកិច្ចការទាំងអស់ក្នុងស្រុក ព្រមទាំងត្រូវជួយរំលឹកដាស់តឿនលោកអនុគណឲ្យបំពេញមុខការរបស់ខ្លួនរឿយ ៗ កុំឲ្យធ្វេសប្រហែស ។

ឃ) ត្រូវបញ្ញត្តហាមផ្ដាច់មិនឲ្យគ្រហស្ថមានអំណាចប្ដឹងពីបព្វជិត ឬជួយឲ្យកម្លាំងគាំទ្រដល់ការប្ដឹងផ្ដល់ វៀរលែងតែករណីណាដែលទាល់ខានពុំបាន ។

ង) បព្វជិត បើទឹងត្រូវការប្ដឹងផ្ដល់លើរូបបព្វជិតណាមួយ ដែលខ្លួនយល់ឃើញថាគួរប្ដឹង ត្រូវសរសេរពាក្យបណ្ដឹងដោយដៃខ្លួនឯង ។

៣– បញ្ហានាទីចៅអធិការវត្ត-នាទីអនុគណ-នាទីមេគណ បញ្ហានេះ មហាសន្និបាតមានយោបល់ព្រមគ្នាថា ត្រូវបង្កើតឲ្យមានច្បាប់ចែងអំពីនាទីឬមុខការ ឬ ករណីយកិច្ច ដែលចៅអធិការវត្ត អនុគណនិងមេគណត្រូវធ្វើ ត្រូវបំពេញ ដើម្បីឲ្យចៅអធិការ, អនុគណនិងមេគណបានស្គាល់នាទី ឬ មុខការរបស់ខ្លួន ហើយនឹងបានបំពេញតាមនាទី ឬមុខការនោះតទៅ ព្រោះសព្វថ្ងៃនេះ មានលោកចៅអធិការខ្លះ អនុគណខ្លះ មេគណខ្លះ ពុំស្គាល់នាទី ឬករណីយកិច្ចរបស់ខ្លួនដោយសព្វគ្រប់ ។

៤– បញ្ហារៀបតាំងគណៈកម្មការគ្រហស្ថ សម្រាប់វត្ត បញ្ហានេះ សម្ដេចព្រះសង្ឃនាយកបានរំលឹកដល់មហាសន្និបាតថា ក្នុងវត្តនីមួយ ៗ គួរតែបង្កើតឲ្យមានគណៈកម្មការគ្រហស្ថ ១ សម្រាប់ជួយកិច្ចការក្នុងវត្តអារាម ដោយរួបរួមទាំងអាចារ្យសម្រាប់វត្តផង ព្រោះគណៈកម្មការគ្រហស្ថនេះជាកម្លាំងមួយក្នុងការជួយដល់កិច្ចការខាងព្រះពុទ្ធសាសនា ។ បើវត្តធំមានព្រះសង្ឃច្រើន គួរបង្កើតឲ្យមានគណៈកម្មការសង្ឃមួយ

ទៀត ។ សម្តេចព្រះសង្ឃនាយកបានបញ្ជាក់ថា រឿងតាំងគណៈកម្មការគ្រហស្ថនេះមានសង្ឃប្រកាស ១ លេខ ៨ ចេញតាំងពីថ្ងៃទី ២ ខែ មេសា គ.ស. ១៩៥៤ ម្ល៉េះ ដោយក្រសួងធម្មការយល់ព្រមផង ។ មហាសន្និបាតបានទទួលព្រមគ្នាថានឹងប្រតិបត្តិតាម ។

៥- បញ្ហាការប្រតិបត្តិសម្រាប់វត្ត (បទបញ្ញា) បញ្ហានេះ ក្រោយដែលសម្តេចព្រះសង្ឃនាយកបានពន្យល់សព្វគ្រប់ហើយ មហាសន្និបាតបានព្រមព្រៀងគ្នាថាគួរបង្កើតឲ្យមាន ព្រោះបទបញ្ញាសម្រាប់វត្តនេះ ជាការមានប្រយោជន៍ណាស់អាចទុកជាច្បាប់សម្រាប់ចៅអធិការ ភិក្ខុ-សាមណេរ ឬ កុមារដែលនៅក្នុងវត្តប្រតិបត្តិធ្វើតាម នាំឲ្យវត្តនីមួយ ៗ មានរបៀបរៀបរយល្អ ។

៦- បញ្ហាការកម្រិតទីព្រំដែនវត្ត បញ្ហានេះ មហាសន្និបាតបានបញ្ចេញយោបល់ជាឯកច្ឆ័ន្ទថា វត្តនីមួយ ៗ គួរឲ្យមានកម្រិតទីដីទៀងទាត់ ហើយគប្បីតែធ្វើកំពែង ឬ គោលចារឹកឲ្យមាំមួន ដើម្បីរក្សាទីដីវត្តឲ្យបានឋិតនៅជាស្ថាពរ ព្រោះទីដីវត្តដែលគ្មានគោលចារឹកមាំមួន ច្រើនតែនាំឲ្យមានអធិករណ៍រវាងគ្រហស្ថដែលនៅជាប់នឹងទីដីវត្ត ។ បញ្ហានេះ មហាសន្និបាតសង្ឃយល់ថា ត្រូវសូមចំពោះរាជរដ្ឋាភិបាលសូមចាត់អ្នករាជការមុខក្រសួងដែលមានសមត្ថកិច្ចឲ្យមេត្តាចាត់ការវាស់វែងកម្រិតទីវត្តឲ្យទៀងទាត់ ចំពោះវត្តណាដែលពុំទាន់កម្រិតទីដី ពុំទាន់មានគោលចារឹកនៅឡើយ ។

៧- បញ្ហារក្សាធរណីសង្ឃគឺទីដីស្រែចំការជាសម្បត្តិសង្ឃ (គរុភណ្ឌ) បញ្ហានេះ មិនមែនមានគ្រប់វត្តអាពមទេ មានចំពោះតែវត្តធំ ៗ វត្តដែលមានទីដីជាបរិវេណនៅជុំវិញវត្ត ឬ ទីដីស្រែចំការដែលនៅឆ្ងាយពីវត្ត ដោយទីដីនោះពុទ្ធបរិស័ទដែលជ្រះថ្លានឹងព្រះពុទ្ធសាសនាបានវេរទុកជាសម្បត្តិសង្ឃសម្រាប់វត្តនីមួយ ៗ ទីដីនោះហៅថាធរណីសង្ឃ ឬ ហៅថា គរុភណ្ឌរបស់សង្ឃ ។ ទីដីបែបនេះច្រើនតែកើតមានអធិករណ៍រវាងអ្នកជួលធ្វើស្រែចំការ ឬ ជួលសង់ផ្ទះលំនៅ ដោយអ្នកជួលនោះ លុះបានធ្វើ ឬ ជួលនៅយូរ ៗ ទៅក៏ប្តឹងដល់រាជការមុខក្រសួងថាជាទីដីកេរ្តិ៍ដំណែលរបស់ខ្លួន ។

មហាសន្និបាតសង្ឃ មានយោបល់ស្របគ្នាសម្រេចថាបញ្ហានេះ សូមរាជការមុខក្រសួងមេត្តាចាត់ឲ្យវាស់វែងកម្រិតទីដីទាំងនោះឲ្យទៀងទាត់ ហើយសូមរាជការទទួលស្គាល់ថាជាធរណីសង្ឃសម្រាប់វត្តនោះ ៗ ដើម្បីកុំឲ្យមានអធិករណ៍ផង ដើម្បីឲ្យទីដីនោះនៅជាសម្បត្តិសង្ឃតទៅផង ។

៨- បញ្ហាចំរើនព្រះបរិត្ត ត្រូវឲ្យមានរបៀប បញ្ហានេះ សម្តេចព្រះសង្ឃនាយកបាន អធិប្បាយពន្យល់យ៉ាងពិស្តារ មហាសន្និបាតបានទទួលប្រតិបត្តិតាមដោយព្រមព្រៀងគ្នា ។

៩- បញ្ហាឲ្យសីលដល់ពុទ្ធបរិស័ទ បញ្ហានេះ សម្តេចព្រះសង្ឃនាយកបានពន្យល់តាំងពីកិច្ច ជាបឋមរហូតដល់ទីបំផុត ដោយការណែនាំបង្ហាត់ឲ្យអានឲ្យត្រូវតាមរយៈឃ្លា ឲ្យមានរបៀប ដើម្បីឲ្យពិធីនេះ មានរបៀបជាឯកភាព ។ មហាសន្និបាតបានទទួលប្រតិបត្តិដោយព្រមព្រៀងគ្នា ។

១០- បញ្ហាទទួលប្រគេនឲ្យត្រូវតាមច្បាប់ បញ្ហានេះ មានក្នុងវិន័យស្រាប់ហើយ សម្តេច ព្រះសង្ឃនាយកបានគម្រូឲ្យព្រះធម្មលិខិត ពន្យល់ដល់មហាសន្និបាតដោយពិស្តារ ។ មហាសន្និបាតបាន ទទួលប្រតិបត្តិតាម ។

១១- បញ្ហាបាំងផ្ចិត ក្នុងពេលឲ្យសីល និងពេលសូត្រធម៌ បញ្ហានេះក្រោយដែលបាន ប្រឹក្សាសន្ទនាតាមគោលការណ៍នៃច្បាប់ព្រះពុទ្ធសាសនា ដើម្បីឲ្យបានសមរម្យ ឲ្យមានរបៀបជាឯកភាពហើយ មហាសន្និបាតបានព្រមគ្នា សម្រេចថាត្រូវបាំងផ្ចិតក្នុងពេលឲ្យសីលនឹងពេលសូត្រធម៌ ក្នុងទីដែលគួរបាំង ។

១២- បញ្ហាជ្រលក់ស្បង់ចីពរ បញ្ហានេះ ក្រោយដែលមហាសន្និបាតបានស្តាប់សេចក្តីពន្យល់ របស់សម្តេចព្រះសង្ឃនាយកថា ក្នុងវិន័យព្រះពុទ្ធសាសនា ពណ៌ស្បង់ចីពរមានតែម្យ៉ាងទេ សព្វថ្ងៃនេះព្រះ- សង្ឃជ្រលក់ស្បង់ចីពរធ្វើឲ្យមានមានពណ៌ផ្សេងៗគ្នា ខ្លះលឿងខ្ចីពេក ខ្លះក្រមៅពេក ខ្លះក្រហមពេក ឃើញ ដូចជាមិនសមរម្យ ។ គួរតែជ្រលក់ឲ្យមានពណ៌ដូចគ្នាតែម្យ៉ាងឲ្យសមដល់ភេទនៃបព្វជិត ដែលកាន់តាមច្បាប់តែ មួយ ។ មហាសន្និបាតបានទទួលប្រតិបត្តិតាមដោយគោរព ឯគំរូពណ៌ក៏បានអនុមតិស្រេចហើយ ។

១៣- បញ្ហាធម៌ចាស់ ធម៌ថ្មី ឬពួកចាស់ ពួកថ្មី បញ្ហានេះ បានរលាយរលត់បាត់អស់ ១៦ ឆ្នាំហើយតាំងពីកាលដែលមានព្រះសង្ឃប្រកាសលេខ ១៦២ ចុះថ្ងៃទី ២១ កញ្ញា ១៩៤៤ ចេញអមព្រះរាជក្រម លេខ ១៦៦ ន.ស. ចុះថ្ងៃទី ១៣ កញ្ញា ១៩៤៤ ហាមប្រាមមិនឲ្យហៅ មិនឲ្យថា ធម៌ចាស់ ធម៌ថ្មីឡើយ ។ ឥឡូវនេះ ត្រឡប់ជាលេចឮឡើងទៀត ។ រីឯពាក្យថា ធម៌ចាស់ ធម៌ថ្មី ឬថា ពួកចាស់ ពួកថ្មីនេះ ជាពាក្យមាន ពិស អាចទុកដូចជាអាវុធសម្រាប់បំបែកបំបាក់សង្ឃគណៈមហានិកាយមិនឲ្យរួបរួមគ្នាកើត ។ ដូច្នេះ មជ្ឈដ្ឋាន សង្ឃមិនគួរនឹងពេញចិត្តយកពាក្យដែលរាជការហាមហើយនោះមកពោលទៀតឡើយ ។

បញ្ហានេះ មហាសន្និបាតសង្ឃបានមូលមតិគ្នាថា ត្រូវបញ្ឈប់ពាក្យថាធម៌ចាស់ ធម៌ថ្មី ឬ ពួកចាស់ ពួកថ្មី កុំឲ្យមានលេចឮទៀត ព្រោះធម៌មានតែមួយ គណៈមហានិកាយក៏មានតែមួយដែរ ។

១៨– បញ្ហាសាមណេរឃុំក្រុង បញ្ហានេះ មានបញ្ញត្តិមកជាយូរហើយ ប៉ុន្តែពុំទាន់បានអនុវត្តឲ្យពេញលេញនៅឡើយ ។ តាំងពីពេលនេះទៅគួរតែគិតរៀបចំព្រមទាំងពន្យល់អំពីច្បាប់ព្រះពុទ្ធសាសនា ដើម្បីឲ្យបព្វជិតបានប្រព្រឹត្តឲ្យមានឯកភាពល្អឡើង ឲ្យសមតាមបញ្ញត្តិរបស់ព្រះពុទ្ធផង ឲ្យស្របនឹងបញ្ញត្តិរបស់រាជការផង ។ ប៉ុន្តែក្នុងការគិតរៀបចំនេះមិនត្រូវបង្ខំទេ ត្រូវរៀបចំតាមសេចក្ដីសមគួរហើយអាចប្រតិបត្តិបានផង ។ មហាសន្និបាតទទួលប្រតិបត្តិតាម ។

១៩– បញ្ហាសំណូមពរចំពោះរាជរដ្ឋាភិបាល កុំឲ្យមានការតិះដៀលព្រះពុទ្ធសាសនាក្នុងសាលាសិក្សារបស់រាជការ ទាំងកុំឲ្យមានការតិះដៀលដោយការសរសេរក្នុងសៀវភៅសម្រាប់សិក្សាណាមួយ បញ្ហានេះ មន្ត្រីសង្ឃដែលនិមន្តមកពីគ្រប់ខេត្តក្នុងព្រះរាជាណាចក្រមកប្រជុំក្នុងមហាសន្និបាត បានសម្ដែងនូវឆន្ទៈស្មើគ្នា សូមពរចំពោះរាជរដ្ឋាភិបាលថា សូមមេត្តាបញ្ញត្តិហាមផ្ដាច់ចំពោះពួកគ្រូបង្ហាត់ គ្រូបង្រៀន និងសាស្ត្រាចារ្យ ដែលបង្រៀនតាំងពីក្នុងសាលាបឋមសិក្សា រហូតដល់សាលាជាន់ខ្ពស់បំផុតកុំឲ្យយករឿងព្រះពុទ្ធសាសនាមកបរិយាយតិះដៀល បន្ទាបបន្ថោករិះគន់ជាពាក្យកំប្លែងលេងសើច ជាអាការមើលងាយ ឬក៏ពន្យល់ឲ្យពួកសិស្សក្នុងសាលារៀន យល់ខុសថាព្រះពុទ្ធសាសនាជាសាសនានាំឲ្យស្រុកទេសទាបថោក ឬ នាំឲ្យស្រុកទេសយឺតដំណើរទៅរកសេចក្ដីចំរើន ។

ពាក្យសំដីបរិយាយបន្ទាបបន្ថោកព្រះពុទ្ធសាសនា របស់ពួកគ្រូបង្រៀនសព្វថ្ងៃនេះមានស្ទើរតែគ្រប់កន្លែង ទាំងសៀវភៅដែលតិះដៀលព្រះពុទ្ធសាសនាក៏មានខ្លះហើយ ដូចជាសៀវភៅការតែងសេចក្ដីខ្មែរ និពន្ធដោយឈ្មោះ គិម-សេត ជាដើម អំពើទាំងនេះនាំឲ្យខូចគុណប្រយោជន៍ច្រើនយ៉ាងគឺ :

ក) មជ្ឈដ្ឋាននៃព្រះសង្ឃដែលកំពុងយកចិត្តទុកដាក់ជួយរដ្ឋាភិបាលក្នុងការស្ថាបនាសាលារៀន ខូចទឹកចិត្ត អស់កម្លាំង ដោយយល់ឃើញថា ការប្រឹងសាងសាលារៀនប្រាកដដូចជាសាងទីកន្លែងសម្រាប់ឲ្យពួកគ្រូញាំញីបំផ្លិចបំផ្លាញព្រះពុទ្ធសាសនាទៅវិញ , សម្រាប់ឲ្យពួកគ្រូឃោសនានាំកុមារកុមារីឲ្យយល់ខុសហើយងាកចិត្តចេញពីព្រះពុទ្ធសាសនា ហើយត្រឡប់ពេញចិត្តនឹងលទ្ធិដទៃមានលទ្ធិកុម្មុយនិស្តជាដើម ។

ខ) យុវជនជាសិស្សសព្វថ្ងៃ ដែលពុំដែលបានទទួលការអប់រំខាងព្រះពុទ្ធសាសនា ជាមនុស្សមាននិស្ស័យទំនេរ កាលបើបានស្តាប់សំដីនិយាយពីព្រះពុទ្ធសាសនា ថាជាសាសនាអាក្រក់រឿយៗទៅ យុវជនទាំងនោះនឹងក្លាយទៅជាមនុស្សសត្រូវនឹងព្រះពុទ្ធសាសនា ។

គ) មិនយូរប៉ុន្មានឆ្នាំទៅមុខ ការបាក់បែកគ្នារវាងអ្នកស្រឡាញ់ព្រះពុទ្ធសាសនានិងអ្នកស្អប់ព្រះពុទ្ធសាសនា នឹងកើតមានឡើងជាប្រាកដ ហើយនឹងជាកង្វល់មួយដ៏ធំសម្បើមក្នុងព្រះពុទ្ធសាសនា នាអនាគត ។

ដោយការយល់ឃើញដូច្នេះ ទើបមហាសន្និបាតបានសម្រេចចិត្តសូមពរចំពោះរាជរដ្ឋាភិបាលដូចខាងលើនេះ ។

១៦– បញ្ហាអប់រំយុវជនខ្មែរ ឲ្យចេះដឹងព្រះពុទ្ធសាសនា បញ្ហានេះ សន្និបាតមានយោបល់ស្របគ្នា ថាត្រូវបង្កើតឲ្យមានគ្រប់វគ្គ ព្រោះជាការមានប្រយោជន៍ណាស់សម្រាប់យុវជនខ្មែរ ប៉ុន្តែដើម្បីឲ្យការអប់រំបានប្រព្រឹត្តទៅស្រួលគួរតែឲ្យមានសៀវភៅជាច្បាប់សម្រាប់អប់រំ ។

បញ្ហាទាំង ១៦ ខាងលើនេះ ដែលមហាសន្និបាតនៃមន្ត្រីសង្ឃមានយោបល់ស្របគ្នា ហើយបានសម្រេចទុកជាផ្លូវប្រតិបត្តិខ្លះ ជាកិច្ចត្រូវបំពេញខ្លះ ដើម្បីឲ្យព្រះសង្ឃក្នុងព្រះរាជាណាចក្រ មានផ្លូវប្រតិបត្តិរៀបរយបណ្តើរៗ ឆ្ពោះទៅរកវឌ្ឍនភាពសមតាមកាលៈទេសៈ ប៉ុន្តែក្នុងបញ្ហាខ្លះទាំងអស់នេះមានបញ្ហាខ្លះព្រះសង្ឃអាចសម្រេចដោយខ្លួនឯងបាន បញ្ហាខ្លះទាក់ទងនឹងដំណើរការនៃរាជរដ្ឋាភិបាល លុះតែរាជរដ្ឋាភិបាលយល់ព្រមទើបអាចនឹងអនុវត្តតាមបាន ដូចមានសេចក្តីបញ្ជាក់តទៅនេះ ៖

ត្រង់បញ្ហាទី ១ អំពីរឿងកឋិន សង្ឃអាចសម្រេចបានខ្លួនឯង ។ ត្រង់បញ្ហាទី ២ សង្ឃមិនអាចសម្រេចខ្លួនឯងបានទេ ព្រោះបញ្ហានេះត្រង់ខទី ៤ នឹងទី ៥ ទាក់ទងនឹងរាជរដ្ឋាភិបាល ។ ត្រង់នេះ សូមក្រសួងធម្មការមេត្តាចាត់ការយ៉ាងណាឲ្យបានទៅជាច្បាប់ ទើបសង្ឃអាចនឹងអនុវត្តតាមបាន ។

ត្រង់បញ្ហាទី ៣ អំពីនាទីចៅអធិការ អនុគណ និង មេគណ ជាការងាយទេ ប៉ុន្តែសព្វថ្ងៃនេះពុំទាន់មានព្រះសង្ឃប្រកាស ឬ ច្បាប់អ្វីបញ្ជាក់ឲ្យដឹងថានាទីចៅអធិការ - អនុគណ - មេគណ យ៉ាងនេះៗ ដើម្បីឲ្យលោកដែលមានតំណែងខាងលើនេះ ប្រតិបត្តិតាម ។ ត្រង់នេះ សូមក្រសួងធម្មការមេត្តាចាត់ការតាំងគណៈកម្មការ ១ ក្រុម មានសង្ឃមានអ្នករាជការគ្រហស្ថក្នុងក្រសួងធម្មការរួមគ្នា ធ្វើនាទី ឬ មុខការសម្រាប់តំណែងសង្ឃខាងលើនេះ

ដើម្បីឲ្យមានការរៀបរយព្រោះនាទីទាំងនេះ សុទ្ធតែទាក់ទងដល់ក្រសួងធម្មការ ។

ត្រង់បញ្ហាទី ៤ អំពីតាំងគណៈកម្មការគ្រហស្ថសម្រាប់វត្ត បញ្ហានេះសង្ឃអាចចាត់ការបានខ្លួនឯងព្រោះរឿងនេះមានព្រះសង្ឃប្រកាសពន្យល់ព្រះសង្ឃគ្រប់វត្តម្តងហើយ ។

ត្រង់បញ្ហាទី ៥ អំពីបទបញ្ញត្តសម្រាប់វត្តក៏មានដំណើរការណ៍ដូចបញ្ហាទី ៣ ដែរ ។

ត្រង់បញ្ហាទី ៦ នឹងទី ៧ អំពីកម្រឹតទីព្រំដែនវត្ត នឹងធរណីសង្ឃគឺទីដីស្រែចំការរបស់សង្ឃ នេះជាបញ្ហាទាក់ទងនឹងកិច្ចការក្រុមផែនទី ។ សូមក្រសួងធម្មការ មេត្តាចាត់ការយ៉ាងណាឲ្យបានក្រុមផែនទីគ្រប់ខេត្ត ជួយបំពេញមុខការនេះឲ្យបានសម្រេចដើម្បីឲ្យទីដីវត្ត នឹងទីដីជាសម្បត្តិសង្ឃបានគង់នៅជាស្ថាពរដោយសុខសាន្តតអង្វែងទៅ ។

ត្រង់បញ្ហាទី ៨, ទី ៩, ទី ១០, ទី ១១ នឹងទី ១២ ជាការៈលើសង្ឃៗ សង្ឃអាចនឹងចាត់ការដោយខ្លួនឯងបានៗ

ត្រង់បញ្ហាទី ១៣ អំពីពាក្យថា ធម្មចាស់ ធម្មថ្មី ដែលហាមមិនឲ្យយកមកនិយាយតទៅទៀតនេះក៏មិនមានជាបញ្ហាអ្វីនាំឲ្យលំបាកទេ ព្រោះមានព្រះសង្ឃប្រកាសដែលចេញអមព្រះរាជក្រមលេខ ១៦៦ ន.ស. ចុះថ្ងៃទី ១៣ កញ្ញា ១៩៤៨ រួចស្រេចទៅហើយ ។ គ្រាន់តែសុំឲ្យក្រសួងធម្មការមានសារាចររំលឹកបន្ថែមជាថ្មីឡើងវិញប៉ុណ្ណោះ ។

ត្រង់បញ្ហាទី ១៤ អំពីសាមណេរឃុំ-គ្រង ក៏ដូចជាបញ្ហាទី ១៣ ដែរ ដោយមានព្រះរាជក្រមបញ្ញត្តរួចស្រេចអស់ហើយ ។

ត្រង់បញ្ហាទី ១៥ អំពីសំណូមពរចំពោះរាជរដ្ឋាភិបាល ។ បញ្ហានេះខាងសង្ឃ ឥតមានអំណាចអ្វីពាល់តែសោះ ។ ត្រង់នេះ សូមក្រសួងធម្មការមេត្តាប្តឹងទៅរាជរដ្ឋាភិបាលសូមឲ្យហាមប្រាមយ៉ាងម៉ឺងម៉ាត់ សូមកុំឲ្យបណ្តែតបណ្តោយឡើយសោះ ព្រោះបញ្ហានេះនាំឲ្យខូចប្រយោជន៍ធំណាស់ ។

ត្រង់បញ្ហាទី ១៦ អំពីការអប់រំយុវជនខ្មែរឲ្យចេះដឹងព្រះពុទ្ធសាសនា ។ អំពីការធ្វើសៀវភៅសម្រាប់អប់រំនោះ សម្ដេចព្រះសង្ឃនាយកបានទទួលភារៈចាត់ការឲ្យបានសម្រេច ។

អធិបតីគណៈកម្មការ

អនុសំវច្ឆរមហាសន្និបាតទី ១៧ នៃមន្ត្រីសង្ឃ

ព្រះពោធិវង្ស

ហា-ត.

បានពិនិត្យឃើញថា

កំណត់ហេតុនេះត្រឹមត្រូវហើយ

ថ្ងៃទី ១៨ មករ ១៩៦១

សម្ដេចព្រះមហាសុមេធាធិបតី

ជ-ណា.

| | |
|---|---|
| អ្នកល្ងង់គេអាច | ណែនាំបានឆាប |
| អ្នកប្រាជ្ញចំណាប់ | រឹតតែឆាប់ណាស់ |
| ឯអ្នកដែលចេះ | ស្ទាក់ស្ទើរពុំច្បាស់ |
| នោះព្រះព្រហ្មម្ចាស់ | ក៏គង់ពុំអាច ។ |

ចាក ត.ល.៣ នៃនីតិសតកៈរបស់ភត្តិហរិ

# អន្តគ្គាហិកទិដ្ឋិកថា

បន្ទាប់តទៅនេះ សូមសំដែងចំពោះទិដ្ឋិ ១០ យ៉ាង ជាទិដ្ឋិប្រកបដោយការយល់ប្រកាន់នូវទីបំផុត ដែលលោកហៅថា អន្តគ្គាហិកទិដ្ឋិ ។ អន្តគ្គាហិកទិដ្ឋិនេះ មានសាខា ១០ យ៉ាង ដូចសេចក្ដីរៀបរាប់ ព្រមទាំងអធិប្បាយពន្យល់សេចក្ដី ដោយសង្ខេបដូចតទៅនេះ

១ – ឃើញថា លោកទៀង ។

២ – លោកមិនទៀង ។

៣ – លោកមានទីបំផុត ។

៤ – លោកមិនមានទីបំផុត ។

៥ – ជីវិតនឹងសរីរៈដូចគ្នា ។

៦ – ជីវិតនឹងសរីរៈផ្សេងគ្នា ។

៧ – សត្វស្លាប់ទៅ រមែងកើតទៀត ។

៨ – សត្វស្លាប់ទៅ រមែងមិនកើតទៀត ។

៩ – សត្វស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ។

១០ – សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។

ពាក្យថា អន្តគ្គាហិកទិដ្ឋិ ប្រែថា ការយល់ឃើញប្រកបដោយសេចក្ដីប្រកាន់នូវទីបំផុត គឺសេចក្ដីយល់ឃើញជ្រុល ទៅខាងស្ដាំផុត ទៅខាងឆ្វេងផុត បានដល់ការយល់ឃើញ ដែលមានកំណាន់ជ្រុលហួសសេចក្ដីពិត លោកចាត់ថាជាទិដ្ឋិ ឃ្លាងចាកសេចក្ដីពិត ដែលពុំមែនជានិយ្យានិកៈ រំលាស់ខ្លួនចេញចាកទុក្ខបានឡើយ គ្រាន់តែជាទិដ្ឋិ នាំឲ្យចម្រូងចម្រាសលង់ខ្លួនប៉ុណ្ណោះ ។

ទិដ្ឋិខាងក្រៅព្រះពុទ្ធសាសនា ទុកជាបញ្ហាសាំញ៉ាំមួយ ដែលមានមកតាំងពីសម័យមុនពុទ្ធកាលសូម្បីព្រះសង្ឃីតិកាចារ្យ ក៏មិនបានអធិប្បាយឲ្យច្បាស់លាស់ អំពីទិដ្ឋិទាំងនេះ ដែលជាបញ្ហាអាចដោះស្រាយបានដោយក្រណាស់ ។ មានតំណាលថា ព្រាហ្មណ៍ឈ្មោះ មាលុង្ក្យៈ ក្រាបទូលសួរព្រះសម្មាសម្ពុទ្ធអំពី

អន្តគ្គាហិកទិដ្ឋិ ១០ យ៉ាង ក្នុងកាលនោះ មាលុង្ក្យៈ ទូលថា បើព្រះអង្គមិនដោះស្រាយទិដ្ឋិទាំងនេះទេ ខ្ញុំព្រះអង្គនឹងមិននៅក្នុងព្រហ្មចរិយធម៌តទៅទៀតទេ ។ បញ្ហាអំពីទិដ្ឋិរបស់មាលុង្ក្យៈ ដែលព្រះសម្ពុទ្ធមិនសំដែងដោះស្រាយ ហៅថា អព្យាកតបញ្ហា ដោយហេតុថា ជាបញ្ហា ឥតប្រយោជន៍ ។

## អធិប្បាយពង្រីកសេចក្តី

១– ពាក្យថា លោក សំដៅយកទាំងពួកសត្វ ទាំងផែនដី ។ ត្រង់ដែលហៅថា លោកទៀងនោះ បានដល់ការយល់ ដែលប្រកបដោយសស្សតទិដ្ឋិ (ការយល់ឃើញថាទៀងទាត់) គឺយល់ឃើញថា ទាំងមនុស្ស ទាំងតិរច្ឆាន សុទ្ធតែមានវិញ្ញាណ ជាដើមពូជរបស់ខ្លួនគ្រប់ៗគ្នា គឺពួកមនុស្សមានអត្តាសម្រាប់មនុស្ស ដាច់ដោយឡែកអំពីតិរច្ឆាន ទើបឯពួកតិរច្ឆាន ក៏មានអត្តាសម្រាប់តិរច្ឆានផ្សេងអំពីមនុស្ស ។ អត្តារបស់មនុស្សនឹងតិរច្ឆាន តែងឋិតនៅជាស្ថាពរប្រចាំលោក មិនអាចប្រែប្រួលបានដោយហេតុណាមួយឡើយ ។

២– លោកមិនទៀង បានដល់ការយល់ឃើញថា លោក គឺពួកសត្វនឹងផែនដី តែងប្រែប្រួល ផ្លាស់ប្តូរទៅបាន តាមហេតុបច្ច័យធម្មតា ដោយកាលវេលារបស់ធាតុទាំង ៤ បង្វិលឲ្យប្រែប្រួលចុះឡើង គឺពួកសត្វទាំងមនុស្សទាំងតិរច្ឆាន អាចធ្លាក់ចុះ អណ្តែតឡើងផ្លាស់ប្តូរ តាមកម្លាំងរបស់ធាតុធម្មតា អាចឲ្យពួកសត្វលិចអណ្តែត ឋិតនៅទៀងទាត់ពុំបាន ។

៣– លោកមានទីបំផុត បានដល់ការយល់ឃើញថា មនុស្សសត្វធ្វើអំពើល្អ ត្រូវទៅកើតក្នុងទីដ៏ល្អដែរ បើធ្វើអំពើអាក្រក់ត្រូវទៅកើតក្នុងទីក៏អាក្រក់ដែរ ឥតមានប្រែប្រួលអ្វីឲ្យហួសអំពីល្អនឹងអាក្រក់ឡើយ ប៉ុន្តែអំពើល្អ អាក្រក់ ស្រេចតែការយល់ឃើញរបស់ខ្លួនៗ មិនចាំបាច់មានទ្រឹស្តីណាមួយ ពន្យល់ថា អំពើនេះល្អ អំពើនេះអាក្រក់ឡើយ ។

៤– លោកមិនមានទីបំផុត បានដល់ការយល់ឃើញថា ការវិលកើតវិលស្លាប់ របស់ពួកសត្វ មិនមានទីបំផុតទេ គឺចេះតែប្រព្រឹត្តទៅមិនដាច់ មិនមានធម៌អ្វីមួយដើម្បីកាត់ផ្តាច់នូវការវិលកើត វិលស្លាប់ របស់ពួកសត្វបានឡើយ ព្រោះថាពួកសត្វតែងកើតឡើងអាស្រ័យធាតុទាំង ៤ កាលបើធាតុមាននៅដរាបណា

ពួកសត្វតែងកើតឡើងជាដរាបនោះ ពុំអាចមានទីបំផុតក្រៅអំពីការកើតស្លាប់ទៀតឡើយ ។

៥– ជីវិតនិងសរីរៈដូចគ្នា បានដល់ការយល់ឃើញរបស់ពួកព្រាហ្មណ៍ខ្លះថា ជីវិតនិងសរីរៈឥតផ្សេងគ្នាទេ ជីវិតក៏គឺសរីរៈ ទើបឯសរីរៈក៏គឺជីវិតហ្នឹងឯង ។

៦– ជីវិតនិងសរីរៈផ្សេងគ្នា បានដល់ការយល់ឃើញរបស់ពួកព្រាហ្មណ៍ខ្លះថា ជីវិតជាតួវិញ្ញាណឬអត្តាដែលជាធម្មជាតមានតែឈ្មោះមិនមានរូបទេ ព្រោះថាជីវិតជានាមធម៌ ប៉ុន្តែអាចបិតនៅក្នុងរូបធម៌គឺសរីរៈ កាលបើសរីរៈបែកធ្លាយ ជីវិតរមែងចេញទៅរកបដិសន្ធិថ្មីទៀតជាដរាប ។ ជីវិតមិនចេះទទួលនូវមរណភាពទេ សរីរៈទើបដល់នូវមរណភាព ។

៧– សត្វស្លាប់ទៅរមែងកើតទៀត បានដល់ការយល់ឃើញថា សត្វស្លាប់ទៅទៀងតែកើតឡើង ប៉ុន្តែការកើតក្នុងកំណើតនៃពួកសត្វណាមួយ នោះពុំអាចកំណត់បានឡើយ គឺស្រេចតែវិញ្ញាណរបស់ពួកសត្វដែលប្រុងអណ្តែតទៅកើតតាមធម្មតា មិនអាចមាននរណាមួយ មើលឃើញបានឡើយ ។

៨– សត្វស្លាប់ទៅមិនកើតទៀត បានដល់ការយល់ឃើញថា ពួកសត្វកាលកើតឡើងក៏កើតឡើងបាន ដោយកាមរតិ របស់បុរសស្ត្រីឯង ៗ លុះស្លាប់ទៅវិញក៏សូន្យឈឹងបាត់ទៅ ឥតមានសល់ធម្មជាតិអ្វីទៅកើតទៀតឡើយ ទិដ្ឋិនេះបានដល់ឧច្ឆេទទិដ្ឋិ ។

៩– សត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន បានដល់ការយល់ឃើញថា ពួកសត្វ កាលបើនៅក្នុងគោត្រជាបុថុជ្ជន លុះស្លាប់ទៅក៏ត្រូវទៅកើតទៀត កាលបើពួកសត្វផុតចាកភាពជាបុថុជ្ជនគោត្រហើយ មិនត្រូវទៅកើតទៀតឡើយ ដោយហេតុផុតពីអំបូរបុថុជ្ជនអស់ហើយ ។

១០– សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន បានដល់ការយល់ឃើញរបស់មនុស្សខ្លះថា ការកើតទៀតនឹងមិនកើតទៀតគ្មានអ្វីជាភស្តុតាងទេ ព្រោះថាកំណើតនៃពួកសត្វនេះ មានហេតុដ៏ល្អិតក្រៃលែងណាស់ ពុំអាចមាននរណាមួយឃើញបាន ដឹងបានដោយច្បាស់ឡើយ ។ ការកើតនឹងមិនកើតនេះ មិនត្រូវមាននរណាមួយហ៊ានបញ្ចេញឲ្យច្បាស់លាស់ឲ្យដាច់ស្រេច ចំពោះការកើតនឹងមិនកើតនោះ

ទេ បើទុកជាមាននរណាមួយសំដែងឧបពោញថា ការកើតនិងការមិនកើតមានពិតប្រាកដ ក៏មិនគួរឲ្យជឿបាន ។ ទិដ្ឋិបែបនេះហៅថា អមរាវិក្ខេបទិដ្ឋិ ប្រែថា ទិដ្ឋិដែលបោះពាក្យសំដីមិនឲ្យស្ទាប់ខ្លួន គឺមិនឲ្យអ្នកផងចាប់ថ្នាក់បាន ។

ទិដ្ឋិទាំង ១០ យ៉ាងនេះ មិនចាត់ថាជាទិដ្ឋិ សុទ្ធតែអាក្រក់ទេ ជាទិដ្ឋិលាយចម្រុះគ្នា ទាំងល្អទាំងអាក្រក់ ដែលគួរកប់ថា ជាទិដ្ឋិសាំញាំពាក់ព័ន្ធនៅក្នុងលោក ជាទិដ្ឋិចាក់ស្រែស រួបរឹតពួកសត្វ ឲ្យវិលវល់មួរនេប នៅក្នុងលោកប្រៀបដូចជាត្រីជាប់សំណាញ់ បេះតែរត់ចេញផ្លាស់ៗ នៅក្នុងសំណាញ់ មិនអាចធ្លាយរួចចាក សំណាញ់បានឡើយ ។

ទិដ្ឋិទាំង ១០ យ៉ាងនេះ គឺត្រង់ទីពីរ ទីបី ទីប្រាំ ទីប្រាំមួយ ទីប្រាំពីរ ទីប្រាំបួន និងទីដប់ ជាទិដ្ឋិគួរកប់ ជាល្អដែរ មិនមែនជាសគ្គាវរណៈ (ហាមឋានមនុស្សសួគ៌) ទេ ជាទិដ្ឋិគួរយកជាការណ៍បាន ប៉ុន្តែទិដ្ឋិទាំងនេះជា មគ្គាវរណៈ (ហាមមគ្គផល) ប៉ុណ្ណោះ ចំណែកខាងទិដ្ឋិទីមួយ ទីបួន ទីប្រាំបី ទើបពេញជាមិច្ឆាទិដ្ឋិ ជា សគ្គាវរណៈផង ជាមគ្គាវរណៈផង ។

ព្រះមុនីកោសល សួរ-ហាយ វត្តឧណ្ណាលោម

អធិបតីរងក្រុមជំនុំប្រែព្រះត្រៃបិដក ។

ប្រែជាអង់គ្លេសដោយលោក គួប-គីឡេង សាស្ត្រាចារ្យ

ភាសាអង់គ្លេសនៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ភ្នំពេញ ។

## DITTHIKĀTHA

### A Discourse on Theory (Continued)

The ten kinds of DITTHI (Viewing or understanding), the theory which is attached only to the end, are classified under the name of ANTAGGĀHIKADITTHI (attachement to the extremes). This ANTAGGĀHIKADITTHI is consisting of ten branches that will be explained one by one as follows:-

1— The belief in the permanency of the world.
2— The belief in the impermanency of the world.
3— The belief in the ending of the world.
4— The belief in the no-ending of the world.
5— The belief in the sameness of life and body.
6— The belief in the difference between life and body.
7— The belief in the rebirth after the death.
8— The belief in the no-rebirth after the death.
9— The belief in the some-reborns and the some-non-reborns after the death.
10— The belief in the no denial in the rebirth and nor in the non-rebirth after the death.

The significant meaning of the word ANTAGGĀHIKA is that it is the understanding on only the ending principles, that is to say, the two extreme ways of believing. This belief stresses the point that one's approach is either beyond right or beyond wrong frontiers. It goes beyond the campus of truth which is, in some places, entitled as Astray-belief. This Astray-belief is non-Buddhistic. It is simply a complicated burden of thoughts. As opposed to this, a Buddhist belief is a non-extreme, that is to say, the belief in the NIYYĀNIKADHAMMA (the doctrine like ship taking passengers from one shore to another shore).

The wrong view theory expounded outside the lines of Buddhism is a complicated question since a very long time. Even the contemporary Buddhist Commentators could not be in a position to give the upto-date explanation.

Verily, there was coming a Brahman named Mālunkya to the Buddha asking Him about the questions of the ten kinds of ANTAGGĀHIKADITTHI belief. Mālunkya, having sat properly, declared that he would not be in the mood to remain bachelor-if a clear explanation could not be given. The Lord's reply was the ABYĀKATĀPAÑHĀ (neutral answer). "This question, oh Mālunkya ! is meaningless", said the Exalted One.

### EXPLANATION

1— The word "Loka" (world) is a very comprehensive one, meaning thereby all the living beings including the earth. The point that the world is permanent means the SASSATADITTHI (the belief in the eternity of the soul). Human beings and animal beings, it is said, have their own seeds, that is VIÑÑĀNA (knowledge) for their reproduction. The group of human beings possess their own ATTĀ (soul), it is further said, totally different from that of animal beings. "The ATTĀS of the two groups are stable and permanent. They have no chance of changing", it is believed.

2— The belief in the impermanency of the world : This belief means that all the beings are uncertain. They will, some way or the other, be forced to take different shapes according to the time in which the four elements prevail. The so-called up-and-down suffering of being like this is, therefore, surnamed as the uncertainly or impermanency of the world.

3— The belief in the ending of the world : One (whether human being or any other being) who does good action will be awarded with a desirable place. If bad action is performed, a bad seat will be the prize. The result of either action has to follow that being like a

shadow. But it is important to emphasize that the two actions (good and bad) depend upon the theory of oneself, and no any other jugment is necessary.

4— The belief in the no-ending of the world : This belief means that there is no an end to the death and rebirth of beings. It is moving like wheel that has no chance to stop. It is because the only composition power of the four elements which could help producing the birth. As long as those elements continue to exist, being will have no way of escaping from death and rebirth at all.

5— The belief in the sameness of life and body : Some Brahmans theorize that life and body are one of the same thing. Life is body and body means life.

6— The belief in the difference between life and body: Life and body, some Brahmans said, do differ from each other. Life, they added, is VIÑÑĀNA (Knowledge) or Attā (self or soul) which is abstract. Life is NAMADHAMMA (doctrine that has simply name) but it can exist easily in RUPADHAMMA (doctrine that has a bodily character). When the body is out of use, life always shifts to another birth. Life is immortal, and body is mortal.

7— The belief in the rebirth after the death : The compensation of death is rebirth. But this rebirth is not assured. It has to proceed according to the law of nature.

8— The belief in the no rebirth after the death : The union of male and female results in the birth of being. But after one is dead, everything is melted spontaneously. This is what is called UCCHEDADITTHI (the belief in the annihilation of soul).

9— The belief in the some-reborns and the some-non-reborns after the death : This doctrine is expounded on the ground that being, being in the worldly atmosphere, has somehow to be reborn. When releasing from this bondage, no more rebirth for him because of the reason that the seed of reproduction has been fully extinguished.

10— The belief in the no denial in the rebirth and nor in the non-rebirth after the death : Some argue that whether one is reborn or not is no question. If reborn, what is the witness ? if not, then what is the ground? The birth of being, they say, is too acute to be perceived and too difficult to be known. Nobody should dare guarantee about this. Even though one could give a correct clue to this problem, there should be none to believe him. This so-belief is called AMARAVIKKHEPADITTHI by name meaning whereby a flattering belief.

The ten kinds of theories or believes as mentioned above are not at all wrong. They are the mixtures of the two sides of view (right and wrong). They are by all means complicated in nature. If putting into practice, they would definitely entangle the whole mental survey of beings thereafter there would be no way out just as fish in the net. 2nd, 3rd, 5th, 6th, 7th, 9th and 10th numbers of these theories, though still defective, are, to a very large extent, desirable. They are not of what is called SAGGĀVARANA (the hindrance to the celestial world). But they are the MAGGĀVARANA (the hindrance to the degrees of sanctity), while 1st, 4th, 8th, numbers are absolutely of Micchādithi (wrong view) because they hinder both the SAGGĀVARANA and the MAGGĀVARANA.

Articled
BY
Venerable PREAH MUNĪKOSALA SOR-HAY
Vice-President of Buddhist Institute.

Translated into English
by
Prof. KUOCH-KYLÉNG
B.A. (University of Delhi)
Buddhist University of Preah Sihanouk Raj
Phnom-Penh, Cambodia.

# ដំណឹងផ្សេងៗ

ក/– នៅថ្ងៃ ១៥ កើតខែពិសាខ ព.ស. ២៥០៤ (២៩-៤-៦១) ពេលរសៀល និងថ្ងៃ ១ រោច តមក ពេលព្រឹក នឹងមានធ្វើបុណ្យនមស្ការ ព្រះសក្យមុនីចេតិយ នៅមុខស្ថានីយ៍អយស្ម័យយាន នាទីក្រុងភ្នំពេញ, ដោយអនុលោមទៅតាមបទបញ្ញត្តិនៃ ព្រះរាជក្រឹត្យ លេខ ១៧៣ ន.ស. ចុះថ្ងៃទី ២៤ មករា គ.ស. ១៩៥៩ ពិធីបុណ្យនេះប្រព្រឹត្តទៅតាមកម្មវិធីផ្លូវការ ដែលក្រសួងធម្មការ នឹងបានចែងផ្សាយក្នុងកាលដ៏គួរ ។

ពុ.ម.កា. និងពុទ្ធសមាគមដទៃទៀតនៅកម្ពុជរដ្ឋ, ដូចរៀងរាល់ឆ្នាំ នឹងត្រូវទទួលភាគការមួយធំនៃពិធីនេះ មានកិច្ចការប៉ុណ្ណេះជាដើមគឺ ៖

នៅល្ងាចថ្ងៃទី ១៥ កើត ចាប់ពីម៉ោង ២០.០០ទៅ ៖ ពិធីវិសាខបូជា ។ ដល់ព្រឹកឡើងគឺថ្ងៃ ១ រោច ៖ ពិធីដាក់បាត្រព្រះសង្ឃជាង ២០០០អង្គ ។

ពុ.ម.កា. អំពាវនាវសូមសមាជិក-សមាជិកា និងពុទ្ធមាមកៈទូទៅ មេត្តាខ្វល់ខ្វាយ អញ្ជើញទៅជួបជុំ នៅបរិវេណព្រះសក្យមុនីចេតិយ ឲ្យបានកុះករ ដើម្បីទទួលភាគផលកុសលតាមប្រាថ្នា ។

ឯកិច្ចនមស្ការក្នុងឱកាសពេលនេះគឺ ៖

មាយវស្សព្វដំសម្ពុទ្ធោ ភគវា យោ តថាគតោ
សមស័ត្យាយុកកាលេ បរិនិព្វាយិ សោ មុនិ
តស្ស សាវិកា ជាតុ អច្ឆរំ បមុខេ ឋិតា
ឥទាកតោ ច សោ សត្ថា ជរមារោ តិដ្ឋតិ
សព្វាវរយាភិឬផេម តំ ឧមស្សាម សាធរំ
សាធុ ខោ ភគវា ធាតោ សព្វញ្ញា សទ្ធាយកោ
ឥមេ ឧល័ទ្ធសក្ការេ អនុកម្បាយ គណ្ហាតុ
ទីឃរត្តំ ហិតាយេវ សុខាយ ម្ហាក សព្វទា ។

«ព្រះតថាគត ភគវន្តមុនី អង្គណា ទ្រង់បានត្រាស់ហើយ (បិតទៅ) អស់កាល ៤៥ ឆ្នាំ, ព្រះតថាគតអង្គនោះ ព្រះអង្គជាមហាមុនី ទ្រង់បរិនិព្វានហើយ ក្នុងកាលដែលព្រះអង្គមានព្រះជន្មាយុ ៨០ ឆ្នាំ

គត់, (ឥឡូវ) ព្រះបរមសារីរិកធាតុនៃព្រះអង្គមកប្រតិស្ឋាន ក្នុងទីចំពោះមុខនៃយើងខ្ញុំព្រះអង្គ ហាក់ដូចជាព្រះបរមសាស្ដាអង្គនោះ ទ្រង់គង់ព្រះធរមាននៅឡើយ ស្ដេចយាងមកគង់ក្នុងទីនេះ យើងខ្ញុំ សូមបូជាចំពោះព្រះអង្គ ដោយគ្រឿងសក្ការៈទាំងឡាយ សូមនមស្ការព្រះអង្គ ដោយគោរព, សូមព្រះភគវន្តមុនី សព្វញ្ញូ-ពុទ្ធ បរមលោកនាថ ដែលតែងតែប្រោសប្រទានសន្តិសុខដល់សត្វលោក ទ្រង់ព្រះមេត្តាប្រោសទទួលនូវគ្រឿងសក្ការៈទាំងឡាយរបស់យើងខ្ញុំព្រះអង្គ ដែលជាសក្ការបូជារបស់អ្នកកំសត់ទុគ៌តនេះ ដើម្បីអនុគ្រោះយើងខ្ញុំព្រះ-អង្គឲ្យបានហិតៈប្រយោជន៍និងសេចក្ដីសុខ សព្វកាលវេលាយូរអង្វែងរៀងទៅហោង ។

(ក្រាបថ្វាយបង្គំ ៣ ដង)

> គេសឹងអាចព្យាយាមដណ្ដើមយកកែវមណីអំពីចង្កូមមាត់មករបាន ;
>
> គេសឹងអាចឆ្លងកាត់សមុទ្រដែលកំពុងរញ្ជួយដោយរលកបោកផ្កាត្រែងបាន ,
>
> គេសឹងអាចយកពស់ ដែលកំពុងខឹងឃោរទូលទេរដាក់លើក្បាលហាក់ដូចជាផ្កាបាន ;
>
> ប៉ុន្តែគេមិនអាចបំពេញចិត្តមនុស្សល្ងង់វង្វេងតែផ្ដាស់បានឡើយ
>
> ចាក គ.ល. ៤ នៃនីតិសតកៈរបស់លោកភត្ត្រីហរី

# ពាក្យសុំចូលជាសមាជិក

នៃពុទ្ធិកសមាគម កម្ពុជរដ្ឋ

ខ្ញុំឈ្មោះ........................ អាយុ.............. ឆ្នាំ, នៅភូមិ........................

ឃុំ........................ ស្រុក........................ ខេត្ត........................

ដោយបានឃើញហើយស្ម័គ្រប្រតិបត្តិតាមលក្ខន្តិកៈនៃពុទ្ធិកសមាគមកម្ពុជរដ្ឋ

សូមចូលក្នុងសមាគមនេះជា........................

ចាប់តាំងពីថ្ងៃទី........................

ព.ស. ២៥០......

ថ្ងៃទី.............. ខែ........................

គ.ស.១៩៦......

បានចុះក្នុងសៀវភៅ — ហត្ថលេខា,

លេខ..............

ចុះថ្ងៃទី..............

## សេចក្តីស្រង់ពីពួក២ នៃលក្ខន្តិកៈរបស់ ពុ.ម.ក.

### ក)– អំពីការឧបត្ថម្ភ

ប្រការ ៤ – ពុ.ម.ក. នៅក្រោមព្រះបរមរាជូបត្ថម្ភនឹងព្រះបរមរាជាធិបតិភាព នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ប្រទេសកម្ពុជា ។

### ១)– អំពីសមាសភាព

ប្រការ ៥ – ពុ. ម. ក. មានសមាសភាពដូចតទៅនេះ៖

សមាជិកកិត្តិយស, ផឧកសមាជិក,

នាយកសមាជិក, កម្មិកសមាជិក,

ចាសានិកសមាជិក ។

បាន: សមាជិកកិត្តិយស – ត្រូវទុកប្រគេន – ជូនពិសេសជនជាន់ខ្ពស់ដូចតទៅនេះ:

ក) សម្តេចព្រះសង្ឃនាយក ទាំងពីរគណៈ នឹងសម្តេចឧត្តមប្រឹក្សា; | គ) ឯកឧត្តមប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ;

ខ) ឯកឧត្តមប្រធានរដ្ឋសភា; | ឃ) ឯកឧត្តមនាយករដ្ឋមន្ត្រី ។

ផឧកសមាជិក គឺជាសមាជិកដែលបានរួបរួមជួយបង្កើត ពុ. ម. ក. បង់ប្រាក់ជូនសមាគម យ៉ាងតិច ៥០០ រៀល ព្រមទាំងបង់ប្រាក់ភាគទាន (១) ប្រចាំខែដូចមានកម្រិតក្នុងប្រការ ៦ ផង ។

(១) - ប្រាក់ដែលសមាជិកគ្រប់ប្រភេទចេញ ។

ទាយកសមាជិក គឺជាសមាជិកដែលធ្វើអំណោយជូនសមាគមយ៉ាងតិច២០០០ រៀល ។

កម្មិកសមាជិក គឺជាសមាជិកដែលបង់ប្រាក់ភាគទានរៀងរាល់ខែ ចំនួន ១០ រៀល ទាំងជាសមាជិកមានធុរៈល្អជួយជានិច្ចកាល មិនចំពោះទីណាកន្លែងណា ឲ្យសមាគមបានចំរុងចំរើនឡើង ។

ទាសាធិកសមាជិក គឺជាសមាជិកដែលមានសោមនស្សចំពោះលទ្ធិនិងកម្មវិធីរបស់សមាគមនេះ សមាជិកប្រភេទនេះអាចជួយសមាគមតាមសេចក្តីជ្រះថ្លារបស់ខ្លួន ។

## តម្លៃជាវ

| | |
|---|---|
| ១ក្បាល | ២៥រ០០ |
| ប្រចាំឆ្នាំ | ៩០រ០០ |

ផ្ញើអាណត្តិប្រៃសណីយ៍ទៅ៖

លោក រស់-ហែម អគ្គហេរញ្ញិកនៃពុទ្ធិក-
សមាគមកម្ពុជរដ្ឋ នៅវត្តឧណ្ណាលោម ភ្នំពេញ

Monsieur **Ros-Hèm** Trésorier
général de l'Association des Bouddhistes
au monastère d'unnalom à Phnom-Penh

មិត្តយើងបោះពុម្ព